# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម

១៣-១០-២០០៥ -ព្រះរាជក្រម នស/រកម/១០០៥/០២៩ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យ ព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិក នៃអនុសញ្ញាស្តីពីការ ការពាររូបកាយ ពីសារធាតុនុយក្លេអ៊ែរ ៦៤៥១

### ២-ព្រះរាជក្រឹត្យ

៣១-១០-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១០០៥/៤៥០ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ជូនឯកឧត្តម និងលោកជំទាវ ចំនួន ០៧ រូប ៦៤៧៥

៣១-១០-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១០០៥/៤៥១ ស្តីពីការតែងតាំងលោកជំទាវ **សុគន្ធ ថាវី** ជានាយករងខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភាទទួលបន្ទុកការងារសង្គមកិច្ច សាសនា និងមនុស្សធម៌ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ៦៤៧៦

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

០៨-១១-២០០៥ -អនុក្រឹត្យលេខ ១២៥ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៦៤៧៧

០៨-១១-២០០៥ -អនុក្រឹត្យលេខ ១២៦ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៦៤៧៩

០៨-១១-២០០៥ -អនុក្រឹត្យលេខ ១២៧ អនក្រ.បក ស្តីពីការផ្តល់ឥណទានថវិកាបន្ថែមលើឥណទានថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ឆ្នាំ ២០០៥ ៦៤៨១

០៧-១១-២០០៥ -អនុក្រឹត្យលេខ ៨០៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៤៨៣

០៧-១១-២០០៥ -អនុក្រឹត្យលេខ ៨០៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៤៨៥

០៧-១១-២០០៥ -អនុក្រឹត្យលេខ ៨១០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៤៨៦

០៧-១១-២០០៥ -អនុក្រឹត្យលេខ ៨១១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៤៨៧

០៧-១១-២០០៥ -អនុក្រឹត្យលេខ ៨១២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៤៨៩

០៧-១១-២០០៥ -អនុក្រឹត្យលេខ ៨១៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦៤៩០

០៧-១១-២០០៥ -អនុក្រឹត្យលេខ ៨១៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៦៤៩១

០៧-១១-២០០៥ -អនុក្រឹត្យលេខ ៨១៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៥៤៣

០៧-១១-២០០៥ -អនុក្រឹត្យលេខ ៨១៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៥៤៤

០៧-១១-២០០៥ -អនុក្រឹត្យលេខ ៨១៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៥៤៥

០៧-១១-២០០៥ -អនុក្រឹត្យលេខ ៨១៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៥៤៧

០៧-១១-២០០៥ -អនុក្រឹត្យលេខ ៨១៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៥៤៨

០៧-១១-២០០៥ -អនុក្រឹត្យលេខ ៨២០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៥៤៩

០៨-១១-២០០៥ -អនុក្រឹត្យលេខ ៨២១ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៦៥៥០

០៨-១១-២០០៥ -អនុក្រឹត្យលេខ ៨២២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៥៥១

០៨-១១-២០០៥ -អនុក្រឹត្យលេខ ៨២៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦៥៥២

០៨-១១-២០០៥ -អនុក្រឹត្យលេខ ៨២៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៥៥៣


## ២-សេចក្តីសំរេច


០៧-១១-២០០៥ -សេចក្តីសំរេចលេខ ៤៨ សសរ ស្តីពីការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីចុះពិនិត្យស្រាវជ្រាវបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋនៅភូមិតានី ឃុំល្វា ស្រុកបវេល ខេត្តបាត់ដំបង ៦៥៥៤


## III-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ


០៣-១១-២០០៥ -ប្រកាសណែនាំលេខ ៧១៧ សហវ.ប្រក.ថ ស្តីពីការបិទបញ្ជីចំណូល-ចំណាយ និងការធ្វើរបាយការណ៍បូកសរុបទូទាត់ចំណូល-ចំណាយថវិការដ្ឋឆ្នាំ ២០០៥ ៦៥៥៦


## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


១១-១០-២០០៥ -លិខិតលេខ ២៣១៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **សៀងហៃ ខនស្ត្រាក់សិន គ្រុប (ខេមបូឌា)** ៦៥៦៧

១១-១០-២០០៥ -លិខិតលេខ ២៣២០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អូស៊ីអានា ស៊ីហ្វូដ ប្រូដាក់** ៦៥៦៩

១១-១០-២០០៥ -លិខិតលេខ ២៣២១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេហ្វ.ឌី.ហ្វាម៉ា** ៦៥៧១

១១-១០-២០០៥ -លិខិតលេខ ២៣២២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ច័ន្ទ តារាស្ទី ខូ អិលធីឌី** ៦៥៧៣

១១-១០-២០០៥ -លិខិតលេខ ២៣២៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ដូប៊ូលី (ខេមបូឌា) អ៊ីមផត អិចផត** ៦៥៧៥

១១-១០-២០០៥ -លិខិតលេខ ២៣៣១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ធីស៊ី មេនផៅវ័រ** ៦៥៧៧

១២-១០-២០០៥ -លិខិតលេខ ២៣៣៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**មួយ ស៊ី & ខេ** ៦៥៧៩

១២-១០-២០០៥ -លិខិតលេខ ២៣៣៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ហេង ហេបភី ខូ អិលធីឌី** ៦៥៨១

១២-១០-២០០៥ -លិខិតលេខ ២៣៣៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ហៀង សុធី ខនស្ត្រាក់សិន គ្រុប** ៦៥៨៣

១២-១០-២០០៥ -លិខិតលេខ ២៣៣៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ធី ស៊ី ខេ ត្រេដ សឺវីស ខូ អិលធីឌី** ៦៥៨៥

១២-១០-២០០៥ -លិខិតលេខ ២៣៣៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស៊ីអេច & ជេ អ៊ិនធើណេសិនណាល** ៦៥៨៧

១២-១០-២០០៥ -លិខិតលេខ ២៣៣៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឌាល អ៊ិនធើរ ឌីវេឡុបមេន (ឌី អាយ ឌី)** ៦៥៨៩

១២-១០-២០០៥ -លិខិតលេខ ២៣៤០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ដឺ ញូ អូសិន** ៦៥៩១

១២-១០-២០០៥ -លិខិតលេខ ២៣៤១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**សៀងហៃ ដានហ្គូន ភ្នំពេញ** ៦៥៩៣

១២-១០-២០០៥ -លិខិតលេខ ២៣៤៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ខេ ជេ អាយ ហូលឌីង ភីធីអ៊ី អិលធីឌី** ៦៥៩៥

១៣-១០-២០០៥ -លិខិតលេខ ២៣៤៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ៊ិនធើប្រ្លធីត មេនេចមេន (ខេមបូឌា) ភីធីអ៊ី អិលធីឌី** ៦៥៩៧

១៣-១០-២០០៥ -លិខិតលេខ ២៣៥០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ម៉ូស៊ីហ្គេន អ៊ិនដាសស្រ្ទី ខូ អិលធីឌី** ៦៥៩៩

១៣-១០-២០០៥ -លិខិតលេខ ២៣៥១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ពិដោ អ៊ិនធើប្រាយ** ៦៦០១

១៣-១០-២០០៥ -លិខិតលេខ ២៣៥៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**យូនីវើសល ឌីវ៉ែកខូ** ៦៦០៣

១៣-១០-២០០៥ -លិខិតលេខ ២៣៥៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ៊ុយ ខួន អ៊ីមផត អិចផត** ៦៦០៥

# ព្រះរាជក្រម

នស / រកម / ១០០៥ / ០២៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិក នៃអនុសញ្ញាស្តីពីការការពាររូបកាយពីសារធាតុនុយក្លេអ៊ែរ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបាន អនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង កាលពីថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យ ប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃ អនុសញ្ញាស្តីពីការការពាររូបកាយពីសារធាតុនុយក្លេអ៊ែរ

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាស្តីពីការការពាររូបកាយពីសារធាតុនុយក្លេអ៊ែរ ដែលធ្វើនៅទីក្រុងវីយ៉ែន នាថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៧៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

**មាត្រា ៣.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុលា ឆ្នាំ ២០០៥

នស/រកម/១០០៥/៤៥៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**សហរដ្ឋមន្ត្រីក្រសួងការពារជាតិ**

**ហត្ថលេខា**

**ទៀ បាញ់ ញឹក ប៊ុនឆៃ**

លេខ ៤០៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុលា ឆ្នាំ ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ាង ឌី តាន់**

៦/៣

# អនុសញ្ញាស្តីពីការការពាររូបកាយពីសារធាតុនុយក្លេអ៊ែរ

**រដ្ឋភាគីទាំងឡាយនៃអនុសញ្ញានេះ**

- ដោយទទួលស្គាល់នូវសិទ្ធិរបស់រដ្ឋទាំងអស់អភិវឌ្ឍន៍ និងប្រើប្រាស់ថាមពលនុយក្លេអ៊ែរ ក្នុងបំណង សន្តិភាព និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួនក្នុងប្រយោជន៍ធំធេង ដែលបានមកពីការប្រើប្រាស់ដោយសន្តិភាព នូវថាមពល នុយ-ក្លេអ៊ែរ

- ដោយជឿលើសេចក្តីត្រូវការចាំបាច់សំរាប់សំរួលកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការប្រើប្រាស់ថាមពល នុយក្លេអ៊ែរ ដោយសន្តិវិធី

- ដោយចង់បញ្ចៀសគ្រោះថ្នាក់ដ៏ធំធេងបង្កឡើងដោយការកាន់កាប់ និងប្រើប្រាស់សារធាតុ នុយក្លេអ៊ែរ ខុសច្បាប់

- ដោយជឿជាក់ថាបទល្មើសទាំងឡាយទាក់ទងនឹងសារធាតុនុយក្លេអ៊ែរ ជាបញ្ហាមួយដែលព្រួយបារម្ភ យ៉ាងខ្លាំង ហើយនិងមានសេចក្តីត្រូវការជាបន្ទាន់ ដើម្បីអនុម័តនូវវិធានការដែលមានប្រសិទ្ធភាព និងសមស្របដើម្បីធានាការទប់ស្កាត់ ការពារ និងការដាក់ទណ្ឌកម្មលើបទល្មើសទាំងនោះ

- ដោយដឹងនូវតំរូវការ នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការបង្កើតវិធានការមានប្រសិទ្ធភាព សំរាប់ការ ការពាររូបកាយពីសារធាតុនុយក្លេអ៊ែរស្របតាមច្បាប់ជាតិរបស់រដ្ឋនីមួយៗ និងស្របតាមអនុសញ្ញានេះ

- ដោយជឿជាក់ថាអនុសញ្ញានេះ ជួយសំរួលដល់ការផ្ទេរដោយសុវត្ថិភាព នូវសារធាតុនុយក្លេអ៊ែរ

-ដោយសង្កត់ធ្ងន់ទៅលើសារៈសំខាន់ដល់ការការពាររូបកាយ ពីសារធាតុនុយក្លេអ៊ែរ ដែលប្រើប្រាស់ស្តុកទុក ហើយ និងការដឹកជញ្ជូននៅក្នុងស្រុក

- ដោយទទួលស្គាល់នូវសារៈសំខាន់នៃការការពាររូបកាយឱ្យមានប្រសិទ្ធភាព ពីសារធាតុនុយក្លេអ៊ែរ ដែលបានប្រើប្រាស់សំរាប់យោធា និងយល់ថាសារធាតុនេះនឹងត្រូវគេបន្តហាមឃាត់ដោយដាច់អហង្ការ ក្នុងការការពាររូបកាយ ។

## មាត្រា ១

## គោលបំណងនៃអនុសញ្ញានេះ

ក- សារធាតុនុយក្លេអ៊ែរ សំដៅលើសារធាតុប្លុយតូនីញ៉ូមទាំងឡាយ លើកលែងតែនៅក្នុងជាតិប្លុយតូនីញ៉ូមនោះ មានការប្រមូលផ្តុំជាអ៊ីសូតូបលើសពី ៨០% នៅក្នុងប្លុយតូនីញ៉ូម-២៣៨.អ៊ុយរ៉ានីញ៉ូម-២៣៣.អ៊ុយរ៉ានីញ៉ូម បង្កនៅក្នុងអ៊ីសូតូប ២៣៥ ឬ ២៣៣.ហើយអ៊ុយរ៉ានីញ៉ូម នោះមានបន្សំនៃអ៊ីសូតូបដែលកើតឡើងពីធម្មជាតិក្រៅពីក្នុងរូបភាពជារ៉ែ ឬកំទេចរ៉ែ សារធាតុទាំងឡាយណាដែលមានការចូលផ្សំពីសារធាតុខាងលើមួយ ឬច្រើន ។

ខ-អ៊ុយរ៉ានីញ៉ូមដែលបង្កនៅក្នុងអ៊ីសូតូប២៣៣ ឬ២៣៥ គឺសំដៅលើធាតុអ៊ុយរ៉ានីញ៉ូមដែលមាននៅក្នុងអ៊ីសូតូប ២៣៣ ឬ ២៣៥ ឬទាំងពីរនៅក្នុងចំនួនមួយដែលអត្រាលើសនៃចំនួនអ៊ីសូតូបទាំងនេះ ចំពោះអ៊ីសូតូប ២៣៨ គឺច្រើនជាងអត្រាអ៊ីសូតូប ២៣៥ បើប្រៀបធៀបទៅនឹងអ៊ីសូតូប២៣៨ កើតឡើងក្នុងធម្មជាតិ ។

គ-"ការដឹកជញ្ជូននុយក្លេអ៊ែរអន្តរជាតិ" មានន័យថាការដឹកជញ្ជូនសារធាតុនុយក្លេអ៊ែរតាមមធ្យោបាយណាក៏ដោយក្នុងគោលបំណងទៅហួសពីទឹកដីនៃរដ្ឋ ដែលការដឹកនេះចាប់ផ្តើមចេញដំណើរពីរដ្ឋដើម ហើយចប់សព្វគ្រប់មកដល់គោលដៅចុងក្រោយនៅក្នុងរដ្ឋដែលទទួល ។

## មាត្រា ២

១-អនុសញ្ញានេះត្រូវអនុវត្តទៅលើសារធាតុនុយក្លេអ៊ែរ ដែលប្រើប្រាស់ក្នុងគោលបំណងសន្តិភាពក្នុងពេល ដឹកជញ្ជូននុយក្លេអ៊ែរជាអន្តរជាតិ ។

២-លើកលែងមាត្រា៣និង៤ ហើយនិងកថាខ័ណ្ឌ ៣នៃមាត្រា៥ អនុសញ្ញានេះត្រូវអនុវត្ត ផងដែរទៅលើការប្រើប្រាស់ដោយសន្តិវិធីនូវពេលប្រើប្រាស់ ស្តុកទុកហើយនិងដឹកជញ្ជូនក្នុងស្រុក ។

៣- ដោយឡែកពីការព្រមព្រៀងមានបញ្ជាក់យ៉ាងច្បាស់ដោយរដ្ឋសមាជិកក្នុងកថាខណ្ឌ ២នៃមាត្រានេះ ដែលទាក់ទងទៅនឹងសារធាតុនុយក្លេអ៊ែរ ដែលប្រើប្រាស់ក្នុងគោលបំណងសន្តិវិធីពេលដែលមានការប្រើប្រាស់ ស្តុកទុក ហើយនិងការដឹកជញ្ជូនក្នុងស្រុកគ្មានអ្វីនៅក្នុងអនុសញ្ញានេះត្រូវបានបកស្រាយថា ប៉ះពាល់លើសិទ្ធិអធិបតេយ្យរបស់រដ្ឋនៅក្នុងការប្រើប្រាស់ ស្តុកទុក ហើយនិងការដឹកជញ្ជូននៅក្នុងស្រុក នៃសារធាតុនុយក្លេអ៊ែរបែបនេះឡើយ ។

## មាត្រា ៣

រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការសមស្របក្នុងក្របខ័ណ្ឌច្បាប់ជាតិរបស់ខ្លួន ហើយនិងស្របទៅតាមច្បាប់អន្តរជាតិ ដែលអាចធានាអោយអនុវត្តទៅបានដើម្បីការពារទៅតាមកំរិតដូចបានពិពណ៌នានៅក្នុងឧបសម្ព័ន្ធ I ក្នុង កំឡុងពេលមានការដឹកជញ្ជូនជាអន្តរជាតិ នូវសារធាតុនុយក្លេអ៊ែរនៅក្នុងទឹកដីរបស់ខ្លួន ឬនៅក្នុងនាវា ឬយន្តហោះ ដែលស្ថិតនៅក្នុងដែនដីរបស់ខ្លួន ក្នុងករណីយន្តហោះនៅជាប់កិច្ចសន្យាដឹកជញ្ជូនទៅ ឬមករដ្ឋនោះ ។

## មាត្រា ៤

១ - រដ្ឋភាគីនីមួយៗមិនត្រូវនាំចេញ ឬផ្តល់សិទ្ធិនាំចេញនូវសារធាតុនុយក្លេអ៊ែរ ប្រសិនបើរដ្ឋនោះមិនបានទទួលការធានា ថាសារធាតុនេះនឹងត្រូវបានការពារក្នុងពេលដឹកជញ្ជូននុយក្លេអ៊ែរជាអន្តរជាតិក្នុងកំរិតដែលមានបញ្ជាក់ក្នុងឧបសម្ព័ន្ធ I

២-រដ្ឋភាគីនីមួយៗមិនត្រូវនាំចូលឬផ្តល់សិទ្ធិនាំចូលនូវសារធាតុនុយក្លេអ៊ែរ ពីរដ្ឋមួយមិនមែនជាភាគីចំពោះពិធីសារនេះ បាន ឡើយ ប្រសិនបើភាគីរដ្ឋនេះមិនបានទទួលការធានារ៉ាប់រងថាសារធាតុបែបនេះ ត្រូវបានការពារទៅតាមកំរិតដូចបានពិពណ៌នា នៅក្នុងឧបសម្ព័ន្ធ I ក្នុងកំឡុងពេលមានការដឹកជញ្ជូននុយក្លេអ៊ែរអន្តរជាតិ ។

៣-រដ្ឋភាគីមួយៗមិនត្រូវអនុញ្ញាតអោយសារធាតុនុយក្លេអ៊ែរ ឆ្លងកាត់ទឹកដីរបស់ខ្លួនតាមផ្លូវគោកឬផ្លូវទឹក ក្នុងឬកាត់តាម អាកាសយានដ្ឋាន ឬកំពង់ផែរបស់ខ្លួនរវាងរដ្ឋដែលមិនមែនជាភាគីចំពោះអនុសញ្ញានេះបានឡើយ ប្រសិនបើរដ្ឋភាគីនេះមិន បានទទួលការធានារ៉ាប់រងតាមដែលអនុវត្តទៅបានថាសារធាតុបែបនេះ ត្រូវបានការការពារទៅតាម កំរិតដូចបានពិពណ៌នា នៅក្នុងឧបសម្ព័ន្ធ I ក្នុងកំឡុងការដឹកជញ្ជូននុយក្លេអ៊ែរអន្តរជាតិ ។

៤- រដ្ឋភាគីនីមួយៗត្រូវអនុវត្តក្នុងក្របខណ្ឌច្បាប់ជាតិរបស់ខ្លួន នូវកំរិតការពាររូបកាយដូចបានពិពណ៌នានៅក្នុង ឧបសម្ព័ន្ធ I ចំពោះសារធាតុនុយក្លេអ៊ែរដែលត្រូវបានដឹកជញ្ជូនពីផ្នែកមួយ នៃរដ្ឋទៅផ្នែកមួយទៀតនៃរដ្ឋដដែល តាមផ្លូវ ទឹក ឬផ្លូវ អាកាសអន្តរជាតិ ។

៥-ភាគីរដ្ឋដែលទទួលខុសត្រូវដល់ការទទួលធានារ៉ាប់រងដែលថា សារធាតុនុយក្លេអ៊ែរត្រូវបានការពារទៅតាមកំរិត ដូចបាន បញ្ជាក់ទៅក្នុងឧបសម្ព័ន្ធ I យោងតាមកថាខ័ណ្ឌ ១ ដល់ ៣ ត្រូវផ្តល់អត្តសញ្ញាណនឹងជូនដំណឹងជាមុនទៅរដ្ឋ ដែលគេរំពឹងថា សារធាតុនុយក្លេអ៊ែរបានឆ្លងកាត់តាមផ្លូវគោកឬផ្លូវទឹក ឬមួយគេរំពឹងថា ចូលទៅក្នុងអាកាស យានដ្ឋាន ឬកំពង់ផែរបស់ រដ្ឋនោះ ។

៦-ការទទួលខុសត្រូវដល់ការទទួលធានារ៉ាប់រង ដែលបានចែងនៅក្នុងកថាខ័ណ្ឌ ១ អាចត្រូវបានផ្ទេរតាមកិច្ចព្រមព្រៀងទៅវិញ ទៅមក ទៅអោយរដ្ឋភាគីដែលជាប់ពាក់ព័ន្ធក្នុងការដឹកជញ្ជូន ខណៈនាំចូលរដ្ឋនោះ ។

៧-គ្មានអ្វីនៅក្នុងមាត្រានេះត្រូវបានបកស្រាយក្នុងរបៀបណាមួយ ដែលថាប៉ះពាល់ទៅលើអធិបតេយ្យនិងយុត្តាធិការរបស់ រដ្ឋណាមួយ ដោយរាប់បញ្ចូលទៅលើផ្លូវអាកាស និងតំបន់សមុទ្ររបស់ខ្លួន។

## មាត្រា ៥

១-រដ្ឋភាគីត្រូវផ្តល់អត្តសញ្ញាណ និងផ្តល់ពត៌មានឱ្យគ្នាដោយផ្ទាល់ ឬតាមរយៈទីភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ ឱ្យដឹង ពីអាជ្ញាធរកណ្តាលរបស់ខ្លួន និងចំណុចទាក់ទងដែលទទួលខុសត្រូវការការពាររូបកាយ នៃសារធាតុនុយក្លេអ៊ែរ ការសំរប សំរួលឱ្យប្រសើរឡើងវិញ ហើយនិង ប្រតិបត្តិការសមស្របក្នុងគ្រាដែលមានការដកចេញការប្រើប្រាស់ ឬការវិភាគសារធាតុ នុយក្លេអ៊ែរដែលគ្មានការអនុញ្ញាត ឬមួយក្នុងគ្រាដែលមានការគំរាមគំហែង ជាយថាហេតុនៅ ក្នុងរដ្ឋនោះ ។

២-ក្នុងករណីមានចោរលួច ប្លន់ ឬការយកសារធាតុនុយក្លេអ៊ែរខុសច្បាប់ណាផ្សេងទៀត ឬមានការគំរាមកំហែង ជាយថាហេតុរដ្ឋភាគីដោយអនុលោមតាមច្បាប់រដ្ឋរបស់ខ្លួន ត្រូវផ្តល់ការសហប្រតិបត្តិការ និងជំនួយអោយបានច្រើន ជាអតិបរិមា ដើម្បីធ្វើឱ្យប្រសើរឡើងវិញ ហើយនិងការពារសារធាតុបែបនេះអោយទៅរដ្ឋណាមួយ ដែលស្នើសុំជា ពិសេសមាន :

ក-រដ្ឋភាគីត្រូវចាត់វិធានការសមរម្យដើម្បីជូនដំណឹងឱ្យបានឆាប់បំផុត ទៅអោយរដ្ឋផ្សេងទៀតដែល ទំនងជាកើតឡើងនូវបទចោរកម្មប្លន់ណាមួយ ឬយកសារធាតុនុយក្លេអ៊ែរខុសច្បាប់ផ្សេង ឬក៏មានការគំរាមកំហែងជាយថាហេតុ ហើយនិងជូនដំណឹងទៅឱ្យអង្គការអន្តរជាតិ ។

ខ-តាមដែលសមស្របនោះ រដ្ឋភាគីដែលជាប់ពាក់ព័ន្ធត្រូវប្តូរពត៌មានគ្នាទៅវិញទៅមក ឬជាមួយនិងអង្គការអន្តរជាតិ ដើម្បីការពារការគំរាមកំហែងដោយសារធាតុនុយក្លេអ៊ែរ ពិនិត្យនូវបូរណភាពនៃកុងទែន័រដឹកជញ្ជូន ឬធ្វើឱ្យប្រសើរឡើងវិញនូវសារធាតុនុយក្លេអ៊ែរ ដែលយកមកខុសច្បាប់ហើយនឹងត្រូវ :

១- សំរបសំរួលកិច្ចខំប្រឹងប្រែងរបស់ខ្លួនតាមផ្លូវការទូត ហើយនិងតាមរយៈបណ្តាញផ្សេង ៗ

២- ផ្តល់ការសង្គ្រោះ បើសិនជាបានស្នើសុំ

៣-ធានាថាបានមកវិញនូវសារធាតុនុយក្លេអ៊ែរដែលត្រូវបានលួច ឬជាលទ្ធផលនៃព្រឹត្តិការណ៍ ដូចមានបញ្ជាក់ខាងលើ ។ មធ្យោបាយនៃការអនុវត្តន៍ ការសហប្រតិបត្តិការនេះត្រូវបានកំណត់ឡើងដោយរដ្ឋភាគី ដែលជាប់ពាក់ព័ន្ធ ។

៣-រដ្ឋភាគីត្រូវធ្វើកិច្ចសហប្រតិបត្តិការ ហើយនិងពិគ្រោះឱ្យបានសមរម្យទៅវិញ ទៅមកដោយផ្ទាល់ ឬតាមរយៈអង្គការអន្តរជាតិ ដើម្បីទទួលយកបានគោលមាគ៌ាស្តីពីការរៀបគំរោង ការថែទាំ ហើយនិងការលើកស្ទួយប្រព័ន្ធ នៃការការពាររូបកាយពីសារធាតុនុយក្លេអ៊ែរ ឱ្យបានប្រសើរឡើងក្នុងការដឹកជញ្ជូនជាអន្តរជាតិ ។

## មាត្រា ៦

១- រដ្ឋភាគីត្រូវចាត់វិធានការសមរម្យស្របតាមច្បាប់រដ្ឋរបស់ខ្លួន ដើម្បីការពារភាពសម្ងាត់នៃពត៌មានណាមួយ ដែលខ្លួនបានទទួលជាសម្ងាត់ស្របតាមបញ្ញត្តិ ដែលមានចែងក្នុងអនុសញ្ញានេះ ពីរដ្ឋភាគីផ្សេងទៀត ឬ តាមរយៈការចូលរួមក្នុងសកម្មភាពណាមួយដែលបានអនុវត្តតាមអនុសញ្ញានេះ ប្រសិនបើភាគីរដ្ឋផ្តល់ពត៌មានទៅអោយអង្គការអន្តរជាតិ ជាសម្ងាត់វិធានការនានាបានត្រូវចាត់ធ្វើឡើងដើម្បីធានាថា ភាពសម្ងាត់នៃពត៌មានបែបនេះត្រូវបានការពារ ។

២- តាមអនុសញ្ញានេះរដ្ឋភាគីមិនត្រូវបានទាមទារឱ្យផ្តល់ពត៌មានណាមួយ ដែលគេមិនអនុញ្ញាតអោយផ្សាយ ដោយអនុលោមតាមច្បាប់រដ្ឋ ឬផ្តល់ពត៌មានណាមួយដែលឱ្យគ្រោះថ្នាក់ដល់សន្តិសុខរដ្ឋដែលជាប់ពាក់ព័ន្ធ ឬការការពាររូបកាយពីសារធាតុនុយក្លេអ៊ែរ ។

## មាត្រា ៧

១- ការប្រព្រឹត្តដោយចេតនាមាន :

ក- អំពើមួយដោយគ្មានអាជ្ញាធរស្របច្បាប់ដែលរាប់បញ្ចូលរួមមាន ការទទួល កាន់កាប់ប្រើប្រាស់ ផ្ទេរ ការកែច្នៃ ការចាក់ចោលសារធាតុនុយក្លេអ៊ែរ ហើយដែលបណ្តាល ឬទំនងជាបណ្តាលឱ្យមានការស្លាប់ ឬរបួសធ្ងន់ដល់បុគ្គលណាមួយ ឬខូចខាតខ្លាំងដល់ទ្រព្យសម្បត្តិ ។

ខ- ការលួចប្លន់ សារធាតុនុយក្លេអ៊ែរ

គ- ការកែបំបាត់ ឬទទួលយកដោយបន្លំនូវសារធាតុនុយក្លេអ៊ែរ

ឃ-អំពើមួយដែលទាមទារយកសារធាតុនុយក្លេអ៊ែរដោយការគំរាមកំហែង ឬប្រើប្រាស់កំលាំង ឬតាមការបំភិតបំភ័យណាមួយ ។

ង- ការគំរាមកំហែងមាន :

ង- ១ ប្រើប្រាស់សារធាតុនុយក្លេអ៊ែរ ដើម្បីបង្កអោយស្លាប់ ឬរបួសធ្ងន់ធ្ងរដល់បុគ្គលណាមួយ ឬធ្វើអោយខូចខាតទ្រព្យសម្បត្តិជាច្រើន ។

ង-២ប្រព្រឹត្តបទល្មើសដូចបានចែងក្នុងវាក្យខ័ណ្ឌ (ខ) ដើម្បីបង្ខិតបង្ខំរូបវន្ត ឬនីតិបុគ្គល អង្គការអន្តរជាតិ ឬរដ្ឋឱ្យធ្វើ ឬហាមប្រាមមិនឱ្យធ្វើនូវអំពើណាមួយ ។

ច- ប៉ុនប៉ងប្រព្រឹត្តបទល្មើសណាមួយដូចបានចែងក្នុងកឋាខ័ណ្ឌ (ក) (ខ) និង (គ) ហើយនិង

ឆ- អំពើណាមួយដែលបានរាប់បញ្ចូលបទល្មើសដូចបានចែងក្នុងកថាខ័ណ្ឌ (ក) ដល់ (ច) រដ្ឋភាគីនីមួយៗត្រូវបង្កើតទណ្ឌកម្មលើបទល្មើសដោយរដ្ឋនីមួយៗ តាមច្បាប់ជាតិរបស់ខ្លួន ។

២-រដ្ឋភាគីត្រូវបង្កើតទណ្ឌកម្មលើបទល្មើសដូចបានចែងក្នុងមាត្រានេះ ហើយត្រូវដាក់ទណ្ឌកម្មសមស្របដោយ គិតពិចារណាដល់ប្រភេទធ្ងន់ធ្ងររបស់បទល្មើស ។

## មាត្រា ៨

១-រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការជាចាំបាច់ ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួនទៅបទល្មើសទាំងនេះ ដូចបានចែងក្នុងមាត្រា៧ ក្នុងករណីខាងក្រោម :

ក-នៅពេលដែលបទល្មើសបានប្រព្រឹត្តឡើងនៅក្នុងទឹកដីនៃរដ្ឋនោះ ឬនៅក្នុងនាវា ឬយន្តហោះ ដែលបានចុះបញ្ជីនៅក្នុងរដ្ឋនោះ

ខ- នៅពេលដែលជនល្មើស ជាជនជាតិណាមួយនៃរដ្ឋនោះ ។

២-រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការជាចាំបាច់ផងដែរ ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួននៅលើបទល្មើសទាំងនេះ ក្នុងករណីដែលជនល្មើសមានវត្តមាននៅក្នុងទឹកដីរបស់ខ្លួន ហើយនិងមិនធ្វើបត្យាប័នជនល្មើសអនុលោមមាត្រា១១ ទៅឱ្យរដ្ឋណាមួយដូចចែងក្នុងកថាខ័ណ្ឌ ១ ។

៣- អនុសញ្ញានេះរាប់បញ្ចូលទាំងយុត្តាធិការឧក្រិដ្ឋកម្មដើម្បីអនុវត្តតាមច្បាប់រដ្ឋ ។

៤-បន្ថែមពីលើនោះទៀតរដ្ឋភាគីដូចដែលមានចែងក្នុងកថាខ័ណ្ឌ ១ និង ២ រដ្ឋភាគីនីមួយៗ ស្របទៅតាមច្បាប់អន្តរជាតិ អាចបង្កើតយុត្តាធិការរបស់ខ្លួន ទៅលើបទល្មើសដែលបានចែងក្នុងមាត្រា ៧ នៅពេលណារដ្ឋភាគីជាប់ពាក់ព័ន្ធក្នុងការដឹកជញ្ជូននុយក្លេអ៊ែរអន្តរជាតិ ខណៈដែលមានការនាំចេញ និងនាំចូលរដ្ឋ ។

## មាត្រា ៩

ដោយពេញចិត្តថាមានការធានាស្ថានភាពបែបនេះ រដ្ឋភាគីនីមួយៗដែលជនល្មើសមានវត្តមាននៅទឹកដីរបស់ខ្លួនត្រូវចាត់វិធានការសមស្របក្នុងនោះមានការ ឃុំឃាំងស្របតាមច្បាប់របស់ខ្លួន ដើម្បីធានាដល់វត្តមានរបស់ជនល្មើស ដើម្បីកាត់ទោសឬធ្វើបត្យាប័ន ។ ការចាត់វិធានការតាមមាត្រានេះ ត្រូវផ្តល់ពតិមានជាលាយល័ក្ខអក្សរ ជាបន្ទាន់ទៅរដ្ឋ ដែលស្នើសុំបង្កើតយុត្តាធិការស្របតាមមាត្រា ៨ ហើយនិងឱ្យទៅរដ្ឋទាំងអស់ដែលជាប់ពាក់ព័ន្ធ ។

## មាត្រា ១០

រដ្ឋភាគីដែលជនល្មើសមានវត្តមាននៅលើទឹកដីរបស់ខ្លួន ប្រសិនបើមិនធ្វើបត្យាប័នជនល្មើសនេះទេ ត្រូវដាក់ជូនដោយគ្មានអញ្ញត្រកម្មជាបន្ទាន់នូវករណីនេះ ទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីកាត់ទោសតាមដំណើររឿងក្តីអនុលោមតាមច្បាប់នៃរដ្ឋនោះ ។

## មាត្រា ១១

១- បទល្មើសនៅក្នុងមាត្រា ៧ ត្រូវបានចាត់ទុកជារួមថា ជាបទល្មើសអាចធ្វើបត្យាប័នបានក្នុងសន្ធិសញ្ញាបត្យាប័នណាមួយដែលមានស្រាប់រវាងរដ្ឋភាគី ។ រដ្ឋភាគីត្រូវចាត់ទុកបទល្មើសទាំងនោះជាបទល្មើសដែល អាចធ្វើបត្យាប័នបាននៅក្នុងរាល់សន្ធិសញ្ញាបត្យាប័នទៅអនាគត ដែលអាចសំរេចបានរវាងគ្នា និងគ្នា ។

២-ប្រសិនបើភាគីរដ្ឋមួយធ្វើបត្យាប័ន ទៅតាមលក្ខខណ្ឌសន្ធិសញ្ញាមួយនោះ ត្រូវទទួលយកការស្នើសុំសំរាប់ធ្វើបត្យាប័នពីរដ្ឋភាគីផ្សេងទៀត ដែលពុំមានសន្ធិសញ្ញាបត្យាប័នតាមជំរើសរបស់ខ្លួនភាគីរដ្ឋនេះ អាចចាត់ទុកអនុសញ្ញានេះ ជាមូលដ្ឋានច្បាប់សំរាប់ធ្វើបត្យាប័នចំពោះបទល្មើសទាំងនោះ ។ ការធ្វើបត្យាប័នត្រូវស្ថិតនៅក្រោមលក្ខខណ្ឌផ្សេងៗ ដែលបានយល់ព្រមដោយច្បាប់រដ្ឋដែលបានស្នើសុំ ។

៣-រដ្ឋភាគីដែលមិនធ្វើបត្យាប័នទៅតាមលក្ខខណ្ឌនៃសន្ធិសញ្ញាមួយនោះ ត្រូវទទួលស្គាល់បទល្មើសទាំងនោះថាជាបទល្មើសដែលអាចធ្វើបត្យាប័នបានរវាងគ្នា និងគ្នាដោយស្ថិតនៅក្រោមលក្ខខណ្ឌនានា ដែលបានយល់ព្រមដោយច្បាប់រដ្ឋ ដែលបានស្នើសុំ ។

៤-វត្ថុបំណងធ្វើបត្យាប័នរវាងរដ្ឋភាគី បទល្មើសនីមួយៗ ត្រូវបានចាត់ទុកជាបទល្មើសដែលបានប្រព្រឹត្តឡើងមិនត្រឹមតែនៅក្នុងកន្លែងដែលបទល្មើសនេះបានកើតឡើងប៉ុណ្ណោះទេ ថែមទាំងនៅក្នុងទឹកដីនៃរដ្ឋភាគីដែលមាន យុត្តាធិការដោយអនុលោមទៅតាមកថាខ័ណ្ឌ ១ ក្នុងមាត្រា ៨ ផងដែរ ។

## មាត្រា ១២

ជនណាក៏ដោយដែលដំណើររឿងក្តីរបស់ខ្លួន ត្រូវបានសំរេចឡើងដោយជាប់ពាក់ព័ន្ធទៅនឹងបទល្មើសណាមួយ ដែលបានចែងនៅក្នុងមាត្រា ៧ ត្រូវបានគេធានាដល់ការប្រព្រឹត្តិត្រឹមត្រូវទៅតាមដំណាក់កាល នៃដំណើររឿងក្តីទាំងអស់ ។

## មាត្រា ១៣

១-រដ្ឋភាគីត្រូវរិះរកវិធានការសង្គ្រោះធំបំផុតពាក់ព័ន្ធទៅនឹងបណ្តឹង ចំពោះបទល្មើសដែលបានចែងក្នុងមាត្រា ៧ ដោយរួមទាំងការផ្តល់ភស្តុតាងនៅហ្នឹងកន្លែងចាំបាច់សំរាប់បណ្តឹង ។ ច្បាប់រដ្ឋដែលបានស្នើសុំត្រូវអនុវត្តតាមគ្រប់ករណី ។

២-បទប្បញ្ញត្តិដែលបានចែងនៅក្នុងកថាខ័ណ្ឌ ១ មិនប៉ះពាល់លើកាតព្វកិច្ចក្នុងសន្ធិសញ្ញាជាទ្វេភាគី ឬពហុភាគីផ្សេងណាមួយដែលគ្រប់គ្រង ឬនឹងគ្រប់គ្រងការសង្គ្រោះគ្នាទៅវិញទៅមក ការសង្គ្រោះគ្នាទាំងមូល ឬជាផ្នែកក្នុងបញ្ហាបទឧក្រិដ្ឋ ។

## មាត្រា ១៤

១- រដ្ឋភាគីនីមួយៗត្រូវជូនដំណឹងអ្នកតំកល់ឯកសារនូវច្បាប់របស់ខ្លួន ហើយនិងបទបញ្ញត្តរបស់ខ្លួនដែលផ្តល់ប្រសិទ្ធិភាពដល់អនុសញ្ញានេះ ។ អ្នកតំកល់ឯកសារត្រូវទាក់ទងផ្តល់ពត៌មាននេះ ទៅឱ្យរដ្ឋភាគីទាំងអស់តាមរយៈកាល ។

២-រដ្ឋភាគីដែលជនល្មើសត្រូវបានកាត់ទោសជាដំបូង ត្រូវទាក់ទងលទ្ធផលចុងក្រោយបណ្តឹងនេះ ទៅឱ្យរដ្ឋដែលជាប់ព័ន្ធដោយផ្ទាល់ ។ រដ្ឋដែលជាសមាជិកត្រូវទាក់ទងផងដែរ នូវលទ្ធផលចុងក្រោយទៅអ្នកតំកល់ដែលត្រូវជូនដំណឹងទៅគ្រប់រដ្ឋ។

៣-នៅកន្លែងដែលបទល្មើសមួយជាប់ទាក់ទិន និងសារធាតុនុយក្លេអ៊ែរ ដែលប្រើប្រាស់សំរាប់បំណងសុខសាន្តសំរាប់ប្រើប្រាស់ ស្តុកទុក និងការដឹកជញ្ជូនក្នុងស្រុក ហើយទាំងជនល្មើស និងសារធាតុនុយក្លេអ៊ែរ នៅតែមាននៅក្នុងទឹកដី នៃរដ្ឋភាគីដែលមានការប្រព្រឹត្តបទល្មើសគ្មានអ្វី នៅក្នុងអនុសញ្ញានេះត្រូវបានបកស្រាយថាចាំបាច់នោះ រដ្ឋភាគីនោះត្រូវផ្តល់ពត៌មានចំពោះដំណើររឿងឧក្រិដ្ឋកម្ម ដែលកើតឡើងចេញពីបទល្មើសនេះទេ ។

## មាត្រា ១៥

ឧបសម្ព័ន្ធនេះបង្កើតជាផ្នែករួមមួយ នៃអនុសញ្ញានេះ ។

## មាត្រា ១៦

១-សន្និសីទនៃរដ្ឋភាគី ត្រូវបានកោះប្រជុំដោយអ្នកតំកល់ឯកសារ ៥ឆ្នាំ ក្រោយពីអនុសញ្ញានេះចូលជាធរមាន ដើម្បីត្រួតពិនិត្យការអនុវត្តន៍អនុសញ្ញានេះ ហើយនិងភាពគ្រាប់គ្រាន់ដែលពាក់ព័ន្ធដល់បុព្វកថា ទាំងផ្នែកប្រតិបត្តិទាំងស្រុង និងឧបសម្ព័ន្ធទាក់ទងស្ថានភាពធរមាន ។

២-ក្នុងចន្លោះពេលមិនលើសពី ៥ ឆ្នាំបន្ទាប់រដ្ឋសមាជិកភាគច្រើនអាចទទួលតាមការដាក់ជូនសំណើ ដែលមានប្រសិទ្ធភាពនេះទៅអ្នកតំកល់ឯកសារ ការកោះប្រជុំសន្និសីទលើកម្មវត្ថុដដែល ។

## មាត្រា ១៧

១-ក្នុងពេលមានជម្លោះមួយរវាងរដ្ឋភាគីពីរ ឬរដ្ឋច្រើនទាក់ទងនិងការបកស្រាយ ឬការអនុវត្តន៍ក្នុងអនុសញ្ញានេះ រដ្ឋភាគីទាំងនោះត្រូវពិគ្រោះយោបល់ ដើម្បីរកដំណោះស្រាយនៃជម្លោះនេះដោយការចរចា ឬដោយមធ្យោបាយសន្តិវិធីផ្សេងទៀតដែលអាចទទួលយកបានចំពោះភាគីជម្លោះទាំងអស់ ។

២-រាល់វិវាទដែលមិនអាចដោះស្រាយបានដូច ដែលមានបញ្ជាក់ក្នុងកថាខ័ណ្ឌ ១ តាមសំណើសុំនៃភាគីជម្លោះត្រូវដាក់ជូនអាជ្ញាកណ្តាល ឬទៅតុលាការយុត្តិធម៌អន្តរជាតិដើម្បីសំរេច ។ បើជម្លោះនេះត្រូវដាក់ជូនអាជ្ញាកណ្តាលក្នុង កំឡុងពេល ៦ខែចាប់ពីថ្ងៃស្នើភាគីជម្លោះមិនអាចព្រមព្រៀងជាមួយអង្គអាជ្ញាកណ្តាលបានទេនោះ ភាគីមួយអាចស្នើសុំប្រធានតុលាការ

យុត្តិធម៌អន្តរជាតិ ឬអគ្គលេខាធិការអង្គការអន្តរជាតិ ដើម្បីតែងតាំងមជ្ឈត្តករមួយ ឬច្រើន ។ ក្នុងករណីជម្លោះស្នើសុំដោយភាគី នៃជម្លោះសំណើទៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិត្រូវមានអាទិភាព ។

៣-នៅពេលចុះហត្ថលេខាផ្តល់សច្ចាប័ន ស៊ីការ អនុម័តលើអនុសញ្ញានេះ ឬក៏ការសុំចូលជាសមាជិកនៃអនុសញ្ញានោះ រដ្ឋសមាជិកមួយ អាចប្រកាសថារដ្ឋខ្លួនមិនបានចាត់ទុកខ្លួនឯងថា ត្រូវជាប់កាតព្វកិច្ចដោះស្រាយវិវាទ ដូចមានចែងក្នុងកថាខ័ណ្ឌ ២ ។ រដ្ឋភាគីផ្សេងទៀតមិនត្រូវជាប់កាតព្វកិច្ចដោះស្រាយវិវាទដូចមានចែងក្នុងកថាខ័ណ្ឌ ២ ទាក់ទងទៅនឹងរដ្ឋសមាជិកដែលធ្វើ Reservation , ចំពោះនីតិវិធីនោះ ។

៤-រដ្ឋភាគីនីមួយៗអាចធ្វើ Reservation ( មាត្រាប៉ំរុង ) អនុលោមតាមកថាខ័ណ្ឌ ៣ អាចដកចេញនូវ Reservation នៅពេលណាក៏បាន តាមរយៈការផ្តល់ពត៌មានទៅឱ្យអ្នកតំកល់ឯកសារ ។

## មាត្រា ១៨

១-អនុសញ្ញានេះត្រូវបើកចំហសំរាប់ចុះហត្ថលេខា ដោយរដ្ឋទាំងអស់នៅទីស្នាក់ការនៃទីភ្នាក់ងារថាមពលអាតូមិក អន្តរជាតិ ក្នុងក្រុងវៀន ហើយនិងនៅទីស្នាក់ការអង្គការសហប្រជាជាតិក្នុងក្រុងញូវយ៉ក ចាប់ពីថ្ងៃទី ០៣ ខែមិនា ឆ្នាំ១៩៨០ រហូតទាល់តែអនុសញ្ញានេះចូលជាធរមាន ។

២- អនុសញ្ញាស្ថិតនៅក្នុងការផ្តល់សច្ចាប័ន ស៊ីការ ការអនុម័តរដ្ឋហត្ថលេខី ។

៣- បន្ទាប់ពីចូលជាធរមាន អនុសញ្ញានេះនឹងបើកចំហសំរាប់ការសុំចូលជាសមាជិកដោយរដ្ឋទាំងអស់ ។

៤- ក-អនុសញ្ញានេះត្រូវបើកចំហសំរាប់ចុះហត្ថលេខា ឬសុំចូលជាសមាជិកដោយអង្គការអន្តរជាតិ និងអង្គការសមាហ័រណកម្មតំបន់ ឬក៏ប្រភេទអង្គការផ្សេងទៀត ប្រសិនបើអង្គការនោះត្រូវបានចាត់តាំងឡើងដោយរដ្ឋអធិបតេយ្យ និងមានសមត្ថភាពការចរចាចុះហត្ថលេខា ហើយនិងអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិនៅក្នុងបញ្ហាទាំងឡាយ ដែលចែងដោយអនុសញ្ញានេះ ។

ខ- បញ្ហានានានៅក្នុងសមត្ថភាពរបស់ខ្លួន អង្គការទាំងនេះក្នុងនាមខ្លួនផ្ទាល់ ត្រូវអនុវត្តសិទ្ធិហើយទទួលខុសត្រូវលើអ្វីដែលអនុសញ្ញានេះសន្មតរដ្ឋជាសមាជិក ។

គ- នៅពេលក្លាយជាភាគីក្នុងអនុសញ្ញានេះ អង្គការនេះត្រូវទាក់ទងជាមួយអ្នកតំកល់ឯកសារនូវសេចក្តីប្រកាស ថាតើរដ្ឋណាដែលជាសមាជិក ហើយមាត្រាណានៃអនុសញ្ញានេះ មិនអនុវត្តទៅលើរដ្ឋនោះ ។

ឃ- អង្គការនេះ មិនត្រូវបោះឱ្យលើរដ្ឋភាគីណាមួយ នៃរដ្ឋសមាជិករបស់ខ្លួនឡើយ ។

៥- ឧបករណ៍នៃសច្ចាប័ន ស៊ីការ ការអនុម័ត ឬសុំចូលជាសមាជិក ត្រូវបានដាក់ជាមួយអ្នកតំកល់ឯកសារ ។

## មាត្រា ១៩

១- អនុសញ្ញានេះត្រូវចូលជាធរមាន ៣០ថ្ងៃ ក្រោយពី ២១ថ្ងៃ នៃការដាក់លិខិតុបករណ៍នៃសច្ចាប័ន ស៊ីការ ការអនុម័ត នៅនឹងអ្នកតំកល់ឯកសារ ។

២-សំរាប់រដ្ឋនីមួយៗ ដែលធ្វើសច្ចាប័ន ស៊ីការ យល់ព្រមការអនុម័តការចូលជាសមាជិកនៃអនុសញ្ញានេះ ក្រោយពី ២១ថ្ងៃ នៃការដាក់លិខិតុបករណ៍ ស៊ីការ ការអនុម័តអនុសញ្ញានេះត្រូវចូលជាធរមាននៅ ៣០ថ្ងៃក្រោយពីដាក់លិខិតុបករណ៍ទាំងនោះដោយរដ្ឋនោះ ។

## មាត្រា ២០

១- ដោយមិនប៉ះពាល់ដល់មាត្រា ១៦ រដ្ឋភាគីមួយអាចដាក់ស្នើវិសោធនកម្មលើអនុសញ្ញានេះ ។ វិសោធនកម្មដែលស្នើឡើងត្រូវបានដាក់ជូនទៅអ្នកតំកល់ឯកសារដែលចែកចាយជាបន្ទាន់ទៅបណ្តារដ្ឋសមាជិក ។ ប្រសិនបើរដ្ឋសមាជិកភាគច្រើនស្នើទៅអ្នកតំកល់ឯកសារអោយកោះប្រជុំសន្និសីទ ដើម្បីពិចារណានូវសំណើវិសោធនកម្ម អ្នកតំកល់ឯកសារនោះ ត្រូវកោះប្រជុំសន្និសីទរដ្ឋទាំងអស់ដើម្បីចាប់ផ្តើមក្រោយ៣០ថ្ងៃពីថ្ងៃដែលធ្វើការអញ្ជើញ ។ រាល់វិសោធនកម្មដែលអនុម័តនៅឯសន្និសីទនោះ ដោយរដ្ឋសមាជិកភាគច្រើន ២ ភាគ ៣ ត្រូវចែកចាយឱ្យបានឆាប់ដោយរដ្ឋ តំកល់ទៅគ្រប់រដ្ឋ ។ វិសោធនកម្មត្រូវចូលជាធរមានសំរាប់រដ្ឋភាគីនីមួយៗ ដែលដាក់លិខិតុបករណ៍នៃសច្ចាប័ន ស៊ីការ ការអនុម័តដល់វិសោធនកម្មនេះ៣០ថ្ងៃក្រោយពីថ្ងៃដែលរដ្ឋ ២ភាគ៣ នៃរដ្ឋភាគីបានដាក់លិខិតុបករណ៍របស់ខ្លួនទាំងនោះ ទៅឱ្យ អ្នកតំកល់ឯកសារ ។ ក្រោយមកវិសោធនកម្មនេះ ត្រូវចូលជាធរមាន សំរាប់ រដ្ឋភាគីផ្សេងណាមួយនៅថ្ងៃដែលរដ្ឋភាគីនោះ ដាក់លិខិតុបករណ៍នៃសច្ចាប័ន ស៊ីការ ការអនុម័តយល់ព្រមដល់វិសោធនកម្មនេះ ។

## មាត្រា ២១

១-រដ្ឋភាគីណាមួយអាចប្រកាសមិនយល់ព្រម ចំពោះអនុសញ្ញានេះដោយធ្វើសេចក្តីប្រកាសពត៌មាន ជាលាយល័កអក្សរជូនទៅអ្នកតំកល់ឯកសារ ។

២-សេចក្តីប្រកាសមិនយល់ព្រមត្រូវចាប់ប្រតិបត្តិ ១៨០ថ្ងៃ បន្ទាប់ពីថ្ងៃអ្នកតំកល់ឯកសារ បានទទួលសេចក្តីប្រកាសពត៌មាននេះ ។

## មាត្រា ២២

អ្នកតំកល់ឯកសារត្រូវជូនដំណឹងជាបន្ទាន់ទៅរដ្ឋទាំងអស់ឱ្យដឹងអំពី :

ក- ការចុះហត្ថលេខានីមួយៗនៃអនុសញ្ញានេះ ។

ខ- ការដាក់លិខិតុបករណ៍នីមួយៗនៃសច្ចាប័ន ស៊ីការ ការអនុម័ត ឬការយល់ព្រម ចូលជាសមាជិក ។

គ- Reservation ឬការដកណាមួយស្របតាមមាត្រា ១៧ ។

ឃ- រាល់ការទំនាក់ទំនងដែលធ្វើឡើងដោយអង្គការ អនុលោមតាមកថាខ័ណ្ឌ ៤ (គ) នៃមាត្រា ១៨ ។

ង- ការចូលជាធរមាននៃអនុសញ្ញានេះ

ច- ការចូលជាធរមាននៃវិសោធនកម្មណាមួយចំពោះអនុសញ្ញានេះ ហើយនិង

ឆ- សេចក្តីប្រកាសមិនយល់ព្រមណាមួយ ដែលបានធ្វើឡើងស្របតាមមាត្រា ២១ ។

## មាត្រា ២៣

ឯកសារដើមនៃអនុសញ្ញានេះ ដែលសរសេរជាភាសា អារ៉ាប៊ីក ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ៉ុល មានតំលៃស្មើគ្នា ត្រូវបានដាក់ជូនទៅឱ្យអគ្គនាយកនៃទីភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ ដែលនឹងត្រូវបញ្ជូនឯកសារចំលងទាំងនោះទៅឱ្យរដ្ឋទាំងអស់ ។

## ឧបសម្ព័ន្ធ I

កំរិតនៃការការពាររូបកាយ ដែលត្រូវបានអនុវត្តក្នុងការដឹកជញ្ជូនអន្តរជាតិនៃសារធាតុនុយក្លេអ៊ែរ ដូចដែលកំណត់នៅក្នុងឧបសម្ពស័ន្ធ II

១-កំរិតនៃការការពាររូបកាយ សំរាប់សារធាតុនុយក្លេអ៊ែរក្នុងកំឡុងការផ្ទុកបន្ទាប់បន្សំ លើការដឹកជញ្ជូននុយក្លេអ៊ែរ អន្តរជាតិនៅក្នុងនោះមាន :

ក- ប្រភេទ ទី IIIសារធាតុទាំងឡាយដែលស្តុកទុកក្នុងតំបន់ដែលគេអាចចូលដល់ ត្រូវបានគេត្រួតពិនិត្យ ។

ខ- ប្រភេទទី II សារធាតុទាំងឡាយដែលស្តុកទុកក្នុងតំបន់ត្រួតពិនិត្យប្រចាំដោយឆ្មាំ ឬសំភារៈអេឡិចត្រូនិកហ៊ុំព័ទ្ធដោយរបាំងការពារ ដែលមានលេខកំណត់នៃចំនុចចូលស្ថិតក្រោមការត្រួតពិនិត្យ ឬផ្នែកណាមួយដែលមានកំរិតស្មើគ្នានៃការការពាររូបកាយ ។

គ- ប្រភេទទី I សារធាតុទាំងឡាយដែលស្តុកទុកក្នុងកន្លែងដែលការពារ ដូចដែលបានកំណត់នៅក្នុងប្រភេទ ទី II ខាងលើដែលប្រភេទនេះ ដែលការសុំចូលស្ថិតនៅលើការទុកចិត្ត ចំពោះបុគ្គលដែលត្រូវបានគេកំណត់ ហើយស្ថិតនៅក្រោមការត្រួតពិនិត្យដោយឆ្មាំ ដែលមានទំនាក់ទំនងជិតស្និទ្ធ ដោយមានកំលាំងឆ្លើយតបសមរម្យ ។ វិធាន ការជាក់លាក់ផ្សេងៗនៅក្នុងបរិបទនេះត្រូវមានជាកម្មវត្ថុនៃការការពារ ទប់ស្កាត់ដល់ការរំលោភបំពានទៅលើការ ចូលដោយគ្មានការអនុញ្ញាត ឬរើរុះដោយគ្មានការអនុញ្ញាតនូវសារធាតុនុក្លេអ៊ែរ ។

២- កំរិតនៃការការពាររូបកាយពីសារធាតុនុយក្លេអ៊ែរ ក្នុងកំឡុងការដឹកជញ្ជូនអន្តរជាតិរួមមាន :

ក- ចំពោះប្រភេទ II និង III សារធាតុទាំងឡាយសំរាប់ការដឹកជញ្ជូននេះត្រូវស្ថិតនៅក្រោមការបង្ការទុក ជាមុន រួមមានការចាត់ចែងជាមុនក្នុងចំណោមអ្នកបញ្ជូនអ្នកទទួល និងអ្នកដឹកជញ្ជូន និងការព្រមព្រៀងជាមុន រវាងរូបមន្ត ឬនីតិបុគ្គលដែលស្ថិតនៅក្រោមយុត្តាធិការ និងបទបញ្ញត្តិនៃរដ្ឋនាំចូល និងនាំចេញដោយកំណត់ពេលវេលា ទីកន្លែង និងនីតិវិធីជាក់លាក់សំរាប់ផ្ទេរការទទួលខុសត្រូវដឹកជញ្ជូន ។

ខ-ចំពោះប្រភេទ I សារធាតុដែលត្រូវដឹកជញ្ជូនត្រូវមាននៅក្នុងការបង្ការទុកជាមុន ដូចមានបញ្ជាក់ខាងលើសំរាប់ការដឹកជញ្ជូននៅក្នុងប្រភេទ II និង IIIហើយស្ថិតនៅក្រោមការត្រួតពិនិត្យប្រចាំ ក្នុងលក្ខខណ្ឌធានាដល់ទំនាក់ទំនងដោយមានការកំណត់ឆ្លើយតបដ៏សមរម្យ ។

គ-ចំពោះអ៊ុយរ៉ានីញ៉ូមធម្មជាតិក្រៅពីមានទ្រង់ទ្រាយជារ៉ែ ឬកំទេចរ៉ែ ការការពារដឹកជញ្ជូនសំរាប់បរិមាណដែលលើសពី ៥០០ គ.ក អ៊ុយរ៉ានីញ៉ូម ត្រូវរាប់បញ្ចូលទាំងការផ្តល់ពត៌មានជាមុននៃការនាំដែលបញ្ជាក់ជាក់លាក់ពី របៀបដឹកជញ្ជូនគិតទុកនូវពេលវេលាមកដល់ និងបញ្ជាក់ការទទួលសំភារៈដឹកនាំឱ្យបានច្បាស់លាស់ ។

## ឧបសម្ព័ន្ធ II

## តារាងបែងចែកប្រភេទនៃសារធាតុនុយក្លេអ៊ែរ

| ល.រ | សារធាតុ | ទ្រង់ទ្រាយ | ប្រភេទ | | |
|---|---|---|---|---|---|
| | | | I | II | III (គ) |
| ១ | ព្លុយតូនីញ៉ូម (ក) | មិនបញ្ចេញពន្លឺ (ខ) | ២ គក ឬលើស | តិចជាង២គក ប៉ុន្តែច្រើនជាង ៥០០ ក្រាម | ៥០០ក្រាម ឬតិចជាង ប៉ុន្តែច្រើនជាង ៩៥ក្រាម |
| ២ | អ៊ុយរ៉ានីញ៉ូម ២៣៥ | មិនបញ្ចេញពន្លឺ (ខ)<br>-អ៊ុយរ៉ានីញ៉ូមមាន ២០% ២៣៥ U ឬលើស<br>-អ៊ុយរ៉ានីញ៉ូមមាន ១០ %២៣៥ U ប៉ុន្តែ តិចជាង ២០ %<br>-អ៊ុយរ៉ានីញ៉ូមមាន លើធម្មជាតិ ប៉ុន្តែតិចជាង ១០% ២៣៥ U | ៥គក ឬលើស<br>---------<br>--------- | តិចជាង៥គក ប៉ុន្តែច្រើនជាង១គក<br>១០គក ឬលើស<br>----------- | ១គក ឬតិច តែលើសពី១៥ក្រាម<br>តិចជាង ១០គក ប៉ុន្តែច្រើនជាង ១គក<br>១០គក ឬលើស |
| ៣ | អ៊ុយរ៉ានីញ៉ូម ២៣៣ | មិនបញ្ចេញពន្លឺ (ខ) | ២គក ឬលើស | តិចជាង២១គក ប៉ុន្តែ ច្រើនជាង៥០០ក្រាម | ៥០០ក្រាមឬតិចជាង តែច្រើនជាង១៥ក្រាម |
| ៤ | ប្រេងដែលបញ្ចេញ ពន្លឺ | | | អ៊ុយរ៉ានីញ៉ូម និងតូនីញ៉ូម ធម្មជាតិ ឬប្រេងឥន្ធនៈ ដែល មានហ្វីស៊ីលតិចជាង ១០% ឃ.ង | |

ក-ព្លុយតូនីញ៉ូម ទាំងអស់លើកលែងតែមានជាតិអ៊ីសូតូប ប្រមូលផ្តុំលើសពី ៨០ % នៅក្នុងព្លុយតូនីញ៉ូម ២៣៨

ខ- សំភារៈមិនបញ្ចេញពន្លឺនៅក្នុងរ៉េអាក់ទ័រ ឬសំភារៈបញ្ចេញពន្លឺនៅក្នុងរ៉េអាក់ទ័រ ប៉ុន្តែមានកំរិតសាយភាយស្មើគ្នា ឬតិចជាង ១00 rads ក្នុងមួយម៉ោងក្នុងមួយម៉ែត្រដែលមិនបានការពារ ។

គ- បរិមាណមិនមាននិយាយក្នុងប្រភេទ III ហើយអ៊ុយរ៉ានីញ៉ូមធម្មជាតិត្រូវបានការពារដោយអនុលោមតាមការ អនុវត្តន៍ការប្រគល់ដីប្រុងប្រយ័ត្ន

ឃ-ទោះជាកំរិតនៃការការពារនេះ ត្រូវបានសំណូមពរក៏ដោយ ក៏វាត្រូវបើកចំហដល់បណ្តារដ្ឋស្ថិតនៅក្រោមការវាយតំលៃដល់ស្ថានភាពជាក់លាក់ ដើម្បីចាត់ជាប្រភេទ នៃការការពាររូបកាយខុសគ្នា ។

ង-ប្រេងឥន្ធនៈផ្សេងៗ ដែលនាំមកនៅសំភារៈហ្វីស៊ីសដើមរបស់វា ត្រូវបានចាត់តាមប្រភេទ I និង II មុនពេល ដែលការបញ្ចេញពន្លឺត្រូវបានកាត់បន្ថយតាមកំរិតប្រភេទ ១ ខណៈដែលកំរិតការសាយភាយចេញពីប្រេងឥន្ធនៈលើស ពី ១០០ rads ក្នុងមួយម៉ោងក្នុងមួយម៉ែត្រដែលមិនបានការពារ ។

# Convention on the Physical Protection of Nuclear Material

## Signed at New York and Vienna, 3 March 1980

THE STATES PARTIES to this Convention,

RECOGNIZING the right of all States to develop and apply nuclear energy for peaceful purposes and their legitimate interests in the potential benefits to be derived from the peaceful application of nuclear energy,

CONVINCED of the need for facilitating international co-operation in the peaceful application of nuclear energy,

DESIRING to avert the potential dangers posed by the unlawful taking and use of nuclear material.

CONVINCED that offences relating to nuclear material are a matter of grave concern and that there is an urgent need to adopt appropriate and effective measures to ensure the prevention, detection and punishment of such offences,

AWARE OF THE NEED for international co-operation to establish, in conformity with the national law of each State Party and with this Convention, effective measures for the physical protection of nuclear material,

CONVINCED that this Convention should facilitate the safe transfer of nuclear material.

STRESSING also the importance of the physical protection of nuclear material in domestic use. storage and transport,

RECOGNIZING the importance of effective physical protection of nuclear material used for military purposes, and understanding that such material is and will continue to be accorded stringent physical protection.

HAVE AGREED as follows:

**ARTICLE 1**

For the purposes of this Convention:

a. "nuclear material" means plutonium except that with isotopic concentration exceeding 80% in plutonium-238; uranium-233; uranium enriched in the isotopes 235 or 233; uranium containing the mixture of isotopes as occurring in nature other than in the form of ore or ore-residue; any material containing one or more of the foregoing;
b. "uranium enriched in the isotope 235 or 233" means uranium containing the isotopes 235 or 233 or both in an amount such that the abundance ratio of the sum of these isotopes to the isotope 238 is greater than the ratio of the isotope 235 to the isotope 238 occurring in nature;
c. "international nuclear transport" means the carriage of a consignment of nuclear material by any means of transportation intended to go beyond the territory of the State where the shipment originates beginning with the departure from a facility of the

shipper in that State and ending with the arrival at a facility of the receiver within the State of ultimate destination.

**ARTICLE 2**

1. This Convention shall apply to nuclear material used for peaceful purposes while in international nuclear transport.
2. With the exception of articles 3 and 4 and paragraph 3 of article 5, this Convention shall also apply to nuclear material used for peaceful purposes while in domestic use, storage and transport.
3. Apart from the commitments expressly undertaken by States Parties in the articles covered by paragraph 2 with respect to nuclear material used for peaceful purposes while in domestic use, storage and transport, nothing in this Convention shall be interpreted as affecting the sovereign rights of a State regarding the domestic use, storage and transport of such nuclear material.

**ARTICLE 3**

Each State Party shall take appropriate steps within the framework of its national law and consistent with international law to ensure as far as practicable that, during international nuclear transport, nuclear material within its territory, or on board a ship or aircraft under its jurisdiction insofar as such ship or aircraft is engaged in the transport to or from that State, is protected at the levels described in Annex 1.

**ARTICLE 4**

1. Each State Party shall not export or authorize the export of nuclear material unless the State Party has received assurances that such material will be protected during the international nuclear transport at the levels described in Annex 1.
2. Each State Party shall not import or authorize the import of nuclear material from a State not party to this Convention unless the State Party has received assurances that such material will during the international nuclear transport be protected at the levels described in Annex 1.
3. A State Party shall not allow the transit of its territory by land or internal waterways or through its airports or seaports of nuclear material between States that are not parties to this Convention unless the State Party has received assurances as far as practicable that this nuclear material will be protected during international nuclear transport at the levels described in Annex 1.
4. Each State Party shall apply within the framework of its national law the levels of physical protection described in Annex I to nuclear material being transported from a part of that State to another part of the same State through international waters or airspace.
5. The State Party responsible for receiving assurances that the nuclear material will be protected at the levels described in Annex I according to paragraphs I to 3 shall identify and inform in advance States which the nuclear material is expected to transit by land or internal waterways, or whose airports or seaports it is expected to enter.
6. The responsibility for obtaining assurances referred to in paragraph I may be transferred, by mutual agreement, to the State Party involved in the transport as the importing State.
7. Nothing in this article shall be interpreted as in any way affecting the territorial sovereignty and jurisdiction of a State, including that over its airspace and territorial sea.

**ARTICLE 5**

1. States Parties shall identify and make known to each other directly or through the International Atomic Energy Agency their central authority and point of contact having

responsibility for physical protection of nuclear material and for co-ordinating recovery and response operations in the event of any unauthorized removal, use or alteration of nuclear material or in the event of credible threat thereof.

2. In the case of theft, robbery or any other unlawful taking of nuclear material or of credible threat thereof, States Parties shall, in accordance with their national law, provide co-operation and assistance to the maximum feasible extent in the recovery and protection of such material to any State that so requests. In particular:
   a. each State Party shall take appropriate steps to inform as soon as possible other States, which appear to it to be concerned, of any theft, robbery or other unlawful taking of nuclear material or credible threat thereof and to inform, where appropriate, international organizations:
   b. as appropriate, the States Parties concerned shall exchange information with each other or international organizations with a view to protecting threatened nuclear material, verifying the integrity of the shipping container, or recovering unlawfully taken nuclear material and shall:
      i. co-ordinate their efforts through diplomatic and other agreed channels:
      ii. render assistance, if requested;
      iii. ensure the return of nuclear material stolen or missing as a consequence of the above-mentioned events.

      The means of implementation of this co-operation shall be determined by the States Parties concerned.
3. States Parties shall co-operate and consult as appropriate, with each other directly or through international organizations, with a view to obtaining guidance on the design, maintenance and improvement of systems of physical protection of nuclear material in international transport.

## ARTICLE 6

1. States Parties shall take appropriate measures consistent with their national law to protect the confidentiality of any information which they receive in confidence by virtue of the provisions of this Convention from another State Party or through participation in an activity carried out for the implementation of this Convention. If States Parties provide information to international organizations in confidence, steps shall be taken to ensure that the confidentiality of such information is protected.
2. States Parties shall not be required by this Convention to provide any information which they are not permitted to communicate pursuant to national law or which would jeopardize the security of the State concerned or the physical protection of nuclear material.

## ARTICLE 7

1. The intentional commission of:
   a. an act without lawful authority which constitutes the receipt, possession, use, transfer, alteration, disposal or dispersal of nuclear material and which causes or is likely to cause death or serious injury to any person or substantial damage to property;
   b. a theft or robbery of nuclear material;
   c. an embezzlement or fraudulent obtaining of nuclear material;
   d. an act constituting a demand for nuclear material by threat or use of force or by any other form of intimidation;
   e. a threat:
      i. to use nuclear material to cause death or serious injury to any person or substantial property damage, or
      ii. to commit an offence described in sub-paragraph (b) in order to compel a natural or legal person, international organization or State to do or to refrain from doing any act;

   f. an attempt to commit any offence described in paragraphs (a), (b) or (c); and
   g. an act which constitutes participation in any offence described in paragraphs (a) to (f) shall be made a punishable offence by each State Party under its national law.
2. Each State Party shall make the offences described in this article punishable by appropriate penalties which take into account their grave nature.

**ARTICLE 8**

1. Each State Party shall take such measures as may be necessary to establish its jurisdiction over the offences set forth in article 7 in the following cases:
   a. when the offence is committed in the territory of that State or on board a ship or aircraft registered in that State;
   b. when the alleged offender is a national of that State.
2. Each State Party shall likewise take such measures as may be necessary to establish its jurisdiction over these offences in cases where the alleged offender is present in its territory and it does not extradite him pursuant to article 11 to any of the States mentioned in paragraph 1.
3. This Convention does not exclude any criminal jurisdiction exercised in accordance with national law.
4. In addition to the States Parties mentioned in paragraphs I and 2, each State Party may, consistent with international law, establish its jurisdiction over the offences set forth in article 7 when it is involved in international nuclear transport as the exporting or importing State.

**ARTICLE 9**

Upon being satisfied that the circumstances so warrant, the State Party in whose territory the alleged offender is present shall take appropriate measures, including detention, under its national law to ensure his presence for the purpose of prosecution or extradition. Measures taken according to this article shall be notified without delay to the States required to establish jurisdiction pursuant to article 8 and, where appropriate, all other States concerned.

**ARTICLE 10**

The State Party in whose territory the alleged offender is present shall, if it does not extradite him, submit, without exception whatsoever and without undue delay, the case to its competent authorities for the purpose of prosecution, through proceedings in accordance with the laws of that State.

**ARTICLE 11**

1. The offences in article 7 shall be deemed to be included as extraditable offences in any extradition treaty existing between States Parties. States Parties undertake to include those offences as extraditable offences in every future extradition treaty to be concluded between them.
2. If a State Party which makes extradition conditional on the existence of a treaty receives a request for extradition from another State Party with which it has no extradition treaty, it may at its option consider this Convention as the legal basis for extradition in respect of those offences. Extradition shall be subject to the other conditions provided by the law of the requested State.
3. States Parties which do not make extradition conditional on the existence of a treaty shall recognize those offences as extraditable offences between themselves subject to the conditions provided by the law of the requested State.
4. Each of the offences shall be treated, for the purpose of extradition between States Parties, as if it had been committed not only in the place in which it occurred but also

in the territories of the States Parties required to establish their jurisdiction in accordance with paragraph I of article 8.

**ARTICLE 12**

Any person regarding whom proceedings are being carried out in connection with any of the offences set forth in article 7 shall be guaranteed fair treatment at all stages of the proceedings.

**ARTICLE 13**

1. States Parties shall afford one another the greatest measure of assistance in connection with criminal proceedings brought in respect of the offences set forth in article 7, including the supply of evidence at their disposal necessary for the proceedings. The law of the State requested shall apply in all cases.
2. The provisions of paragraph I shall not affect obligations under any other treaty, bilateral or multilateral, which governs or will govern, in whole or in part, mutual assistance in criminal matters.

**ARTICLE 14**

1. Each State Party shall inform the depositary of its laws and regulations which give effect to this Convention. The depositary shall communicate such information periodically to all States Parties.
2. The State Party where an alleged offender is prosecuted shall, wherever practicable, first communicate the final outcome of the proceedings to the States directly concerned. The State Party shall also communicate the final outcome to the depositary who shall inform all States.
3. Where an offence involves nuclear material used for peaceful purposes in domestic use, storage or transport, and both the alleged offender and the nuclear material remain in the territory of the State Party in which the offence was committed, nothing in this Convention shall be interpreted as requiring that State Party to provide information concerning criminal proceeding arising out of such an offence.

**ARTICLE 15**

The Annexes constitute an integral part of this Convention

**ARTICLE 16**

1. A conference of States Parties shall be convened by the depositary five years after the entry into force of this Convention to review the implementation of the Convention and its adequacy as concerns the preamble, the whole of the operative part and the annexes in the light of the then prevailing situation.
2. At intervals of not less than five years thereafter, the majority of States Parties may obtain, by submitting a proposal to this effect to the depositary, the convening of further conferences with the same objective.

**ARTICLE 17**

1. In the event of a dispute between two or more States Parties concerning the interpretation or application of this Convention, such States Parties shall consult with a view to the settlement of the dispute by negotiation, or by any other peaceful means of settling disputes acceptable to all parties to the dispute.

2. Any dispute of this character which cannot be settled in the manner prescribed in paragraph I shall, at the request of any party to such dispute, be submitted to arbitration or referred to the International Court of Justice for decision. Where a dispute is submitted to arbitration, if, within six months from the date of the request, the parties to the dispute are unable to agree on the organization of the arbitration, a party may request the President of the International Court of Justice or the Secretary-General of the United Nations to appoint one or more arbitrators. In case of conflicting requests by the parties to the dispute, the request to the Secretary-General of the United Nations shall have priority.
3. Each State Party may at the time of signature, ratification, acceptance or approval of this Convention or accession thereto declare that it does not consider itself bound by either or both of the dispute settlement procedures provided for in paragraph 2. The other States Parties shall not be bound by a dispute settlement procedure provided for in paragraph 2, with respect to a State Party which has made a reservation to that procedure.
4. Any State Party which has made a reservation in accordance with paragraph 3 may at any time withdraw that reservation by notification to the depositary.

**ARTICLE 18**

1. This Convention shall be open for signature by all States at the Headquarters of the International Atomic Energy Agency in Vienna and at the Headquarters of the United Nations in New York from 3 March 1980 until its entry into force.
**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៨១៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ឈន សារ៉ាំណែ** ហៅ **ឈន សារ៉ាំណេ** អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន អស់ចំនួន ១០១.៩០០ ដុល្លារ និង ប្រាក់រៀល ចំនួន ១.៦៩០.០០០ រៀល ដើម្បីចូលរួមជួយកសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈនានារបស់ជាតិ និងកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០៥*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

R.209

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៧១៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសមាគម និងសប្បុរសជនជប៉ុន ដែលបានឧបត្ថម្ភថវិកា ជួយកសាងសាលារៀន នៅខេត្តកំពង់ធំ ដូចមានខាងក្រោម :-

១-សមាគម GEDATSU- KAI ឧបត្ថម្ភថវិកា ចំនួន ១៧.០៣៤.៥៦ ដុល្លារអាមេរិក សំរាប់ជួយកសាងអគារសិក្សា ០១ខ្នង មាន០៣បន្ទប់ បំពាក់ដោយសម្ភារីមគ្រប់គ្រាន់ បង្គន់អនាម័យ ០៤ បន្ទប់ និងអណ្តូងទឹក ០១ នៅសាលាបឋមសិក្សា ជាំ ឃុំតាំងក្រសៅ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ។

២-លោកស្រី TOMIE KUWABARA ប្រធានអង្គការ Happy Apple ឧបត្ថម្ភថវិកា ចំនួន ២៤.០០០ ដុល្លារអាមេរិក សំរាប់ជួយកសាងអគារសិក្សា ០១ខ្នង មាន០៤បន្ទប់ បំពាក់ដោយសម្ភារីមគ្រប់គ្រាន់ បង្គន់អនាម័យ ០១ខ្នង ខ្លោងទ្វារ ដងទង់ជាតិ និង អណ្តូងទឹក នៅសាលាបឋមសិក្សាស្លែង ឃុំតាំងក្តីដូង ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
SR.177 -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៩២០...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី **OSANAI MIEKO** ប្រធានអង្គការ **Japan Team of Young Human Power ( JHP )** ដែលបានឧបត្ថម្ភថវិកា ចំនួន ១៩.០០០ ដុល្លារអាមេរិក សំរាប់សាងសង់អគារសិក្សា ០១ខ្នង នៅសាលាបឋមសិក្សាសាគូរ៉ា ក្បាលជ្រោយ ក្នុងសង្កាត់ជ្រោយចង្វារ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៩៧១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនសប្បុរសជន ជប៉ុន ចំនួន០៤រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការ ជាមួយព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោមនេះ :-

១-Mr. MUTUHIRO TAKAHASHI . PRESIDENT ; " MUTSUKI KOGYO CORPORATION " Co. Ltd. ; JAPAN .

២-H.E. Mr. HIROMICHI WATANABE . A MEMBER OF PARLIAMENT ; JAPAN .

៣-Mr. HIROFUMI SAEKI . PRESIDENT ; " SHINKO " Co. Ltd ; JAPAN .

៤-Mr. KAZUO OKUBO . SENIOR ADVISER ; " SHINKO " Co. Ltd ; JAPAN .

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ.ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..៩២៣....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០២គ្រឿង ជូនសប្បុរសជន ចំនួន០២រូប ដែលបានខិតខំស្វែងរកជំនួយ ដើម្បីជួយជាជំនួយឥតសំណងដល់ ព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម :-

១-លោក **ហ្គោ សូម៉ាន់ថា** ( Mr.GO SO MANTHA ) MANAGER ; " MUTSUKI KOGYO CORPORATION " Co. Ltd ; JAPAN .

២-លោក **នួន ម៉េងឃាង** ប្រធាន " SOLAR POWER " Co. Ltd ; CAMBODIA .

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ.ថ្ងៃទី ០៧ ខែ ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៧២៣.....អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តពោធិ៍សាត់

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ សេនា ជូនឯកឧត្តម **តាន់ គីមវិន់** អគ្គនាយកអគ្គិសនីកម្ពុជា ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផល លើវិស័យអប់រំ កសិកម្ម ព្រះពុទ្ធសាសនា វិស័យគមនាគមន៍ និងជួយប្រជាពលរដ្ឋ ដើម្បីរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល នៅក្នុងខេត្តពោធិ៍សាត់ សរុបទឹកប្រាក់ចំនួន ១៣០.៩៣៥ ដុល្លារ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ០៨ វិច្ឆិកា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ១ និង មាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ...អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តពោធិ៍សាត់

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកជំទាវ **ជា ខេង** ភរិយាឯកឧត្តម **ស៊ុយ សែម** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផល លើវិស័យអប់រំ កសិកម្ម ព្រះពុទ្ធសាសនា វិស័យគមនាគមន៍ និងជួយប្រជាពលរដ្ឋ ដើម្បីរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល នៅក្នុងខេត្តពោធិ៍សាត់ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៤៨ សសរ**

## សេចក្ដីសំរេច

## ស្ដីពី

ការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីចុះពិនិត្យស្រាវជ្រាវបណ្ដឹង តវ៉ារបស់ប្រជាពលរដ្ឋនៅភូមិតានី ឃុំល្វា ស្រុកបវេល ខេត្តបាត់ដំបង

---

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដី ពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី .
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ .
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ំ រេ ច

**ប្រការ១** : បង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីចុះពិនិត្យស្រាវជ្រាវបណ្ដឹងតវ៉ារបស់ប្រជាពលរដ្ឋចំនួន ១១២គ្រួសារនៅភូមិតានី ឃុំល្វា ស្រុកបវេល ខេត្តបាត់ដំបង ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១- តំណាងក្រសួងមហាផ្ទៃ | ប្រធាន |
| ២- តំណាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៣- តំណាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ៤- តំណាងក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ | សមាជិក |

៥- តំណាងអគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល ក្រសួងមហាផ្ទៃ សមាជិក

៦- តំណាងអភិបាលខេត្តបាត់ដំបង សមាជិក

៧- តំណាងយោធភូមិភាគ៥ សមាជិក

**ប្រការ២ :** គណៈកម្មការនេះមានភារកិច្ចសហការជាមួយអាជ្ញាធរដែនដីគ្រប់ថ្នាក់ដែលពាក់ព័ន្ធ ចុះពិនិត្យស្រាវជ្រាវ និង សំរបសំរួលបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋ ចំនួន ១១២គ្រួសារ នៅភូមិតានី ឃុំល្វា ស្រុកបវេល ខេត្តបាត់ដំបង ដែលពាក់ព័ន្ធនឹងដីធ្លី ចំនួន ៣៦០ហិកតា និង ព្រមទាំងខិតខំប្រមែប្រមូលឯកសារ សំខាន់ៗ និងពត៌មានពិតជាក់ស្តែង ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

**ប្រការ៣ :** សមាជិកទាំងអស់របស់គណៈកម្មការត្រូវចូលរួមប្រជុំ និង ចុះបំពេញភារកិច្ចតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រីបណ្តាក្រសួង ប្រធានស្ថាប័នដែលពាក់ព័ន្ធ ព្រមទាំងសមាសភាពក្រសួងមានចែងក្នុងប្រការ១ មានភារកិច្ចទទួលអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
( ដើម្បីជូន និងថ្វាយជ្រាប )
- ដូចប្រការ ១ និង ៤
"ដើម្បីអនុវត្ត"
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៧១៧ សហវ.ប្រក-ថ

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ ២០០៥

# ប្រកាសណែនាំ
# ស្តីពី
# ការបិទបញ្ជីចំណូល-ចំណាយ និង
# ការធ្វើរបាយការណ៍បូកសរុបទូទាត់ចំណូល-ចំណាយថវិការដ្ឋឆ្នាំ២០០៥

- យោងច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និង ច្បាប់ទាំងឡាយដែលធ្វើវិសោធនកម្មច្បាប់នេះ ។

- យោងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៤/០០២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០៤ ។

- យោងអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋនៅតាមក្រសួង-ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល ។

- យោងអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ។

- យោងអនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០១ ស្តីពីនីតិវិធីនៃការបើកផ្តល់មុនដោយអាណត្តិបើកប្រាក់សំរាប់ :

  - ចំណាយដំណើរការរៀបចំការបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
  - ចំណាយមូលនិធិសំរាប់ជួសជុលថែទាំផ្លូវថ្នល់
  - ចំណាយសំរាប់កម្មវិធីអភិវឌ្ឍន៍សុខាភិបាលស្រុកប្រតិបត្តិឈានមុខ (ADD) និងចំណាយសំរាប់កម្មវិធីសកម្មភាពជាអាទិភាព (PAP) ។

- យោងអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០៤ ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៥

- យោងអនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០៤ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៥ ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ដោយឆ្នាំថវិកាត្រូវចាប់ផ្តើមពីថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ (មាត្រា ៤ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីនីតិវិធីបច្ចេកទេស ដើម្បីធានាឱ្យការបិទបញ្ជីចំណូល-ចំណាយនិងការធ្វើរបាយការណ៍បូកសរុបទូទាត់ចំណូល-ចំណាយថវិកាទូទៅរបស់រដ្ឋ ឆ្នាំ ២០០៥ ប្រព្រឹត្តទៅបានត្រឹមត្រូវ និង ទាន់ពេលវេលាដូចតទៅនេះ :

**I- អំពីការបិទបញ្ជីចំណូល-ចំណាយថវិការដ្ឋឆ្នាំ ២០០៥**

**ក-អំពីចំណូលថវិការដ្ឋ**

ចំណូលថវិកាទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធដកចំណូលយកទៅចំណាយតាមទំនើងចិត្ត ឬមួយពន្យាពេលបង់ចូលថវិការដ្ឋ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ (ភាគទី III និងមាត្រា១០៦ នៃ អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ) ។ ដូចនេះ **ប្រាក់ចំណូលទាំងអស់ត្រូវតែប្រមូលបង់ចូលថវិការដ្ឋយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ជាកំហិត ។**

**ខ-អំពីចំណាយថវិការដ្ឋ**

ការបិទបញ្ជីចំណាយ (មាត្រា ១០៧ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ) ត្រូវដំណើរការទៅតាមដំណាក់កាលចំណាយនិងពេលវេលាដូចតទៅ :

* **ទិដ្ឋាការនៃការសន្យាចំណាយ** ក្រៅពីចំណាយបៀវត្ស និងចំណាយសំរាប់គោលនយោបាយសង្គមកិច្ច **មិនអាចអនុវត្តក្រោយថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ បានទេ** (មាត្រា ១០៨ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៥ )។ ដូច្នេះគ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវប្រញាប់ប្រញាល់រៀបចំបែបបទឯកសារ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមបំណាច់ខែតុលា ឆ្នាំ ២០០៥ ដើម្បីទុករយៈពេល ១០ ថ្ងៃអោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុពិនិត្យ និង សំរេច ចុះទិដ្ឋាការធានាចំណាយជូនតាមការជាក់ស្តែង។ ក្នុងករណីមាន**ចំណាយចាំបាច់មិនអាចខានបាននិងមានឥណទានថវិកាសល់ទំនេរ** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តពិនិត្យធានាចំណាយជូន តែក៏**មិនឱ្យហួសពីថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែរ** ហើយទិដ្ឋាការនេះ ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (មាត្រា ២០ នៃអនុក្រឹត្យលេខ ៨១ អនក្រ. បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ) ។

* **រាល់ការសន្យាចំណាយដែលអាណត្តិបើកប្រាក់មិនបានធ្វើឡើងនៅមុនថ្ងៃទី ៣១ ខែ ធ្នូ នៃ ឆ្នាំ ២០០៥ ត្រូវបានបដិសេធចោល ហើយត្រូវសុំធ្វើការធានាចំណាយជាថ្មីដោយប្រើប្រាស់ឥណទានថវិកានៃឆ្នាំបន្ទាប់** (មាត្រា ១០៩ នៃ អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ) ។

* រតនាគារជាតិនិងរតនាគារខេត្ត-ក្រុង **ត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់ត្រឹមវេលាម៉ោង ១៧ និង ៣០នាទី នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥** លើកលែងអាណត្តិប្រាក់បៀវត្សនិងប្រាក់គោលនយោបាយសង្គមកិច្ចនិងអាណត្តិនិយ័តកម្ម(មាត្រា១១១ អនុក្រឹត្យលេខ ៨២អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥)។ ដូច្នេះ ក្រសួង-ស្ថាប័នត្រូវប្រមូលសក្ខីប័ត្រនិងលិខិតយុត្តិការដែលបញ្ជាក់ពីសេវាដែលបានធ្វើរួចហើយ ដើម្បី**ធ្វើអាណត្តិបើកប្រាក់ ហើយបញ្ជូនទៅឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៥** ។ ដោយឡែក មន្ទីរជំនាញខេត្ត-ក្រុង ត្រូវបញ្ជូនអាណត្តិបើកប្រាក់ដែលបានឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួចហើយ**ទៅអភិបាលខេត្ត-ក្រុងពិនិត្យចុះហត្ថលេខា ឱ្យបានមុនថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៥** ។

គ-<u>អំពីចំណាយរដ្ឋទេយ្យបុរេប្រទាននិងថវិកាបុរេប្រទាន</u>

* **រដ្ឋទេយ្យករបុរេប្រទាន** ត្រូវប្រមែប្រមូលលិខិតយុត្តិការចំណាយដើម្បីធ្វើអាណត្តិនិយ័តកម្ម (ទូទាត់) **យ៉ាងយូរបំផុតក្នុងរយៈពេលមួយខែ** ដោយគិតចាប់ពីកាលបរិច្ឆេទដកសាច់ប្រាក់ពីរតនាគារជាតិ ឬ រតនាគារខេត្ត-ក្រុង (មាត្រា ៦៧ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ) លើកលែងតែក្នុងខែធ្នូ នៃឆ្នាំ រតនាគារជាតិ ឬ រតនាគារខេត្ត-ក្រុង ត្រូវ**បញ្ឈប់ការដកសាច់ប្រាក់ចុងក្រោយបង្អស់ពីគណនីរដ្ឋទេយ្យបុរេប្រទាន នៅម៉ោង ១៧ និង ៣០នាទី នាថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៥** ។ ក្នុងរយៈពេលពី**ថ្ងៃទី ១៥ ដល់ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៥** រដ្ឋទេយ្យករបុរេប្រទានត្រូវរួតរះប្រមូលឯកសារ និងលិខិតយុត្តិការចំណាយរួចធ្វើអាណត្តិនិយ័តកម្មឆ្លងទិដ្ឋាការ រួចបញ្ជូនទៅរតនាគារជាតិ ឬ រតនាគារខេត្ត-ក្រុង **ត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥** ជាកំហិត ។

* **ថវិកាបុរេប្រទាន** គឺជាការបើកផ្តល់ចំណាយមុនដែរ ក្នុងករណីមានការចាំបាច់បន្ទាន់ ដូច្នេះការទូទាត់ថវិកាបុរេប្រទាននេះក៏ត្រូវរួតរះប្រមូលឯកសារសុំ**ទូទាត់ឱ្យបានមុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥** ដោយគិតរួមទាំងចំណាយថវិកាបុរេប្រទានជារូបិយប័ណ្ណអន្តរជាតិ ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានផ្តល់ជូនតាមរយៈមូលប្បទានប័ត្រ ។ **ក្នុងករណីប្រាក់បុរេប្រទានឆ្នាំ២០០៥ ដែលមិនបានធ្វើការទូទាត់ឱ្យអស់នោះទេ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងកាត់ទុកឥណទានថវិកាពាក់ព័ន្ធក្នុងក្របខ័ណ្ឌថវិកាឆ្នាំ ២០០៦ មុននឹងធ្វើការធានាចំណាយសំរាប់ឆ្នាំ២០០៦** ។

ដោយឡែក ថវិកាបុរេប្រទានដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**បានបើកផ្តល់ជូនមុនបណ្តោះអាសន្នដោយអាណត្តិបើកប្រាក់**ជូនក្រសួង-ស្ថាប័ន **ដោយផ្អែកតាមអនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០១** រដ្ឋទេយ្យករនៃក្រសួង-ស្ថាប័ននេះ ត្រូវខិតខំប្រមូលឯកសារនិងលិខិតយុត្តិការចំណាយទាំងអស់តាមចំនួនទឹកប្រាក់ក្នុងអាណត្តិបើកប្រាក់នីមួយៗ ដើម្បីត្រៀមរង់ចាំធ្វើសវនកម្មក្រោយចំណាយ។

ក្នុងករណីមានការខ្វះខាតឥណទានថវិកាសំរាប់ធ្វើការទូទាត់រដ្ឋទេយ្យបុរេប្រទាន ឬ បុរេប្រទានរដ្ឋទេយ្យករត្រូវរាយការណ៍ជាបន្ទាន់ទៅអាណាប័ក ដើម្បីមានវិធានការតាមការជាក់ស្តែង ជាអាទិ៍ :

- លើកសំណើសុំធ្វើនិយ័តភាពថវិកាផ្ទៃក្នុងដែលសល់ទំនេរមកបំពេញឱ្យខ្ទង់ថវិកាដែលត្រូវធ្វើអាណត្តិនិយ័តកម្ម ក្នុងនោះគិតរួមទាំងប្រាក់បុរេប្រទានឆ្នាំមុនៗផងដែរ ។

- កាត់បន្ថយ ឬផ្អាកជាបណ្តោះអាសន្ននូវទឹកប្រាក់បានធានាចំណាយមួយចំនួនដែលមិនសូវចាំបាច់សំដៅធ្វើការជំរះបញ្ជីចំណាយថវិកាបុរេប្រទាននេះឱ្យបានជ្រះស្រឡះ ។

**<u>ឃ-អំពីចលនាឥណទាន</u>**

ការ**ធ្វើនិយ័តភាពថវិកា**ផ្ទៃក្នុងជំពូកសំរាប់ការទូទាត់ចំណាយចាំបាច់ឬទូទាត់រជ្ជទេយ្យបុរេប្រទាន ឬទូទាត់បុរេប្រទាន **ត្រូវបញ្ចប់ នៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៥** ។ ដូច្នេះ ក្រសួង-ស្ថាប័ននិងមន្ទីរជំនាញតាមខេត្ត-ក្រុងទាំងអស់ត្រូវបញ្ជូនសំណុំលិខិតស្នើសុំធ្វើនិយ័តភាពឥណទានមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **យ៉ាងយូរត្រឹមថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៥** ។

**<u>ង-កិច្ចប្រតិបត្តិការនិយ័តកម្មនៃរតនាគារ</u>**

កិច្ចប្រតិបត្តិការនិយ័តកម្មនៃរតនាគារសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ **ត្រូវបន្តរហូតដល់ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៦** ( មាត្រា ១១១ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ) ។ កិច្ចប្រតិបត្តិការនេះត្រូវពិនិត្យកត់ត្រាជាលេខនាបន្ថែម ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលទាក់ទងទៅនឹង :

* ការកត់ត្រាជាស្ថាពរនៃចំណូល ឬចំណាយដែលបានពិនិត្យកត់ត្រាជាលេខនា មុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ជាអាទិ៍ ចូលគណនីកត់ត្រាបណ្តោះអាសន្ន ។

* អាណត្តិនិយ័តកម្មដែលទាក់ទងដល់ចំណាយដែលបានទូទាត់ដោយរជ្ជទេយ្យបុរេប្រទាន និង បុរេប្រទាន មុនថ្ងៃទី ៣១ ខែ ធ្នូ ។

* ការកែតម្រូវលេខនាខុស ។

* កិច្ចប្រតិបត្តិការប្រមូលកិច្ចការគណនេយ្យករនៃអង្គភាពរដ្ឋបាលហិរញ្ញវត្ថុ និងគណនេយ្យកររងនៃរតនាគារខេត្ត-ក្រុង ។

**<u>ច-កិច្ចប្រតិបត្តិការថវិកាឆ្នាំ ២០០៦</u>**

១- ចាប់ពីថ្ងៃទី **០១ ខែ ធ្នូ ឆ្នាំ ២០០៥** ក្នុងករណីមាន**ភាពប្រញាប់លើឥណទាននៃឆ្នាំបន្ទាប់** (**២០០៦** ) ការសន្យាចំណាយអាចធ្វើបានក្នុងកំរិត **១/១២ នៃឥណទានប្រចាំឆ្នាំកំពុងប្រព្រឹត្តទៅ** ( **២០០៥** ) ( មាត្រា ១១០ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ) ។

២- ចាប់ពីថ្ងៃទី **០១ ខែ មករា ឆ្នាំ ២០០៦** តទៅ រាល់កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិការដ្ឋឆ្នាំថ្មី **ត្រូវកត់ត្រាចូលក្នុងគណនីថវិការដ្ឋឆ្នាំ ២០០៦** ។

៣- រាល់កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិការដ្ឋឆ្នាំ ២០០៦ ត្រូវផ្អែកលើកម្មវិធីចំណូល-ចំណាយប្រចាំខែ និង ត្រីមាស ដែលក្រសួង-ស្ថាប័ន រដ្ឋបាលកណ្តាល និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវរៀបចំ និង ធ្វើ

មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ក្នុងរយៈពេល ០២ សប្តាហ៍ ក្រោយពីកញ្ចប់ថវិកាត្រូវបានអនុម័ត ។

II- **ការធ្វើរបាយការណ៍បូកសរុបទូទាត់ចំណូល-ចំណាយថវិកាទូទៅរបស់រដ្ឋឆ្នាំ ២០០៥**

ការបូកសរុបសម្រេចទូទាត់ថវិកាទូទៅរបស់រដ្ឋឆ្នាំ ២០០៥ ត្រូវដំណើរការដូចតទៅ :

* ចាប់ពីថ្ងៃទី **០១ ខែ កុម្ភៈ ឆ្នាំ ២០០៦** រតនាគារជាតិត្រូវដំណើការបូកសរុបកិច្ចប្រតិបត្តិការរតនាគារទូទាំងប្រទេសអំពីការអនុវត្តចំណូល-ចំណាយថវិការដ្ឋឆ្នាំ២០០៥ ហើយបញ្ជូនរបាយការណ៍បូកសរុបនេះ ព្រមទាំងតារាងតុល្យភាពគណនីជាស្ថាពរមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) **យ៉ាងយូរត្រឹម ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៦** ។

* ចាប់ពីថ្ងៃទី **០១ ខែ មករា ឆ្នាំ ២០០៦** គ្រប់មន្ទីរជំនាញខេត្ត-ក្រុង ត្រូវធ្វើការផ្ទៀងផ្ទាត់តួលេខចំណូល-ចំណាយរបស់អង្គភាពខ្លួនឱ្យបានត្រូវគ្នាជាមួយរតនាគារនិងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយធ្វើរបាយការណ៍បូកសរុបទូទាត់ថវិការបស់ខ្លួន រួចផ្ញើមកមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងសាមី**ចំនួន ០២ច្បាប់ ឱ្យបានមុនថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៦** ។

មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានភារៈកិច្ចបូកសរុបទូទាត់ចំណូល-ចំណាយរបស់មន្ទីរជំនាញនៅខេត្ត-ក្រុង រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ( នាយកដ្ឋានថវិកា ) **ចំនួន០២ច្បាប់ ឱ្យបាន មុនថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៦ ជាកំហិត** ។

ចំពោះក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាលត្រូវផ្ទៀងផ្ទាត់តួលេខចំណូល-ចំណាយថវិការបស់ខ្លួនជាមួយរតនាគារជាតិ នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ (ចំពោះចំណាយមូលធន) និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដើម្បីឱ្យបានត្រូវគ្នា ហើយធ្វើរបាយការណ៍បូកសរុបទូទាត់ចំណូល-ចំណាយថវិការបស់ស្ថាប័នខ្លួនដោយមានបញ្ចូលចំណូល-ចំណាយថវិការបស់មន្ទីរជំនាញនានាក្រោមឱវាទ នៅតាមខេត្ត-ក្រុងផង រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) **ចំនួន ០២ច្បាប់ ឱ្យបាន មុនថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៦ ជាកំហិត** ។

ក្រសួង-ស្ថាប័ននិងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅតាមខេត្តក្រុងត្រូវធ្វើរបាយការណ៍បូកសរុបទូទាត់របស់ខ្លួនទៅតាមតារាងគំរូដែលមានភ្ជាប់មកជាមួយនេះ រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ( នាយកដ្ឋានថវិកា ) ឱ្យបានតាមកាលកំណត់ខាងលើជាកំហិត ដើម្បីឱ្យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានលទ្ធភាពធ្វើការបូកសរុបរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៥ ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសម្រេច និង ស្ថាប័ននីតិបញ្ញត្តិអនុម័តឱ្យបានទាន់ពេលវេលា ។

ក្នុងករណីក្រសួង-ស្ថាប័ន និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅតាមខេត្ត-ក្រុងណាផ្ញើរបាយការណ៍បូកសរុបទូទាត់របស់ខ្លួនមិនបានទាន់ពេលវេលាកំណត់ខាងលើទេ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងផ្អែកតាមតួលេខរបាយការណ៍បូកសរុបរបស់ធនាគារជាតិជាផ្លូវការ ។

គ្រប់ក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាល ធនាគារជាតិ ធនាគារខេត្ត-ក្រុង មន្ទីរជំនាញខេត្ត-ក្រុង និងនាយកដ្ឋានពាក់ព័ន្ធទាំងឡាយ ត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ចម្លងជូនៈ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អាជ្ញាធរសវនកម្មជាតិ
  (ដើម្បីជូនជ្រាបជាពត៌មាន)
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាល
- នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន
- ធនាគារជាតិ
- គ្រប់មន្ទីរជំនាញតាមខេត្ត-ក្រុង
- គ្រប់អភិបាលខេត្ត-ក្រុង
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត-ក្រុង
- ធនាគារខេត្ត-ក្រុង
  (ដើម្បីអនុវត្ត)
- ឯកសារនិងកាលប្បវត្តិ

ទេសរដ្ឋមន្ត្រី ៧/ ៥
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

# តារាងសរុបចំណូលថវិការដ្ឋ
# សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥

| ជំពូក | ប្រការ | កថាខណ្ឌ | វាក្យខណ្ឌ | បរិយាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | អនុវត្តជាក់ស្តែង | សមមាត្រប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤-៣/២ | |
| | | | | I - ផ្នែករដ្ឋបាលកណ្តាល | | | | |
| | | | | II-ផ្នែកមន្ទីរជំនាញខេត្ត-ក្រុង | | | | |
| | | | | សរុបរួម | | | | |

| | | | |
|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខា | ហត្ថលេខា |
| ប្រធានធនាគារជាតិ | រដ្ឋមន្ត្រី | ប្រធានគណនេយ្យ | អ្នកធ្វើតារាង |

# តារាងសរុបចំណាយថវិការដ្ឋ
## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥

| ជំពូក | ប្រការ | កថាខណ្ឌ | អនុកថាខណ្ឌ | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ដើមឆ្នាំ | ចលនាឥណទាន | | ស្ថានភាព ឥណទានថ្មី | អនុវត្តជាក់ស្តែង | សមមាត្រ ប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | + | - | | | | |
| | | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧=៦/៥ | |
| | | | | I - ផ្នែករដ្ឋបាលកណ្តាល<br>១. ចំណាយចរន្ត<br><br>២. ចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស<br><br>II- ផ្នែកមន្ទីរជំនាញខេត្ត-ក្រុង | | | | | | | |
| | | | | សរុបរួម | | | | | | | |

| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខា | ហត្ថលេខា |
|---|---|---|---|
| ប្រធានធនាគារជាតិ | រដ្ឋមន្ត្រី | ប្រធានគណនេយ្យ | អ្នកធ្វើតារាង |

## តារាងសរុបចំណាយវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស
## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥

ឯកតា: ពាន់ដុល្លាអាមេរិក

| លេខគំរោង | ឈ្មោះគំរោង | ប្រភពជំនួយ | ប្រភេទជំនួយ | រយៈពេល អនុវត្តគំរោង | តំលៃគំរោង | គំរោង ឆ្នាំ ២០០៥ | អនុវត្តជាក់ស្តែង ឆ្នាំ ២០០៥ |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| សរុបរួម | | | | | | | |

ហត្ថលេខានិងត្រា
រដ្ឋមន្ត្រី

ហត្ថលេខា
ប្រធានគណនេយ្យ

ហត្ថលេខា
អ្នកធ្វើតារាង

# តារាងសរុបចំណាយថវិការដ្ឋ
# សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥

| ជំពូក | ប្រការ | កថាខណ្ឌ | អនុកថាខណ្ឌ | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ដើមឆ្នាំ | អនុវត្តជាក់ស្តែង | សមមាត្រ ប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤-៣/២ | |
| | | | | | | | | |
| | | | | សរុបរួម | | | | |

ហត្ថលេខានិងត្រា
ប្រធានធនាគារខេត្ត-ក្រុង

ហត្ថលេខានិងត្រា
អភិបាលខេត្ត-ក្រុង

ហត្ថលេខានិងត្រា
ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា
ប្រធានគណនេយ្យ

ហត្ថលេខា
អ្នកធ្វើតារាង

# តារាងសរុបចំណាយថវិការដ្ឋ
## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥

| ជំពូក | ប្រការ | កថាខណ្ឌ | វាក្យខណ្ឌ | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ដើមឆ្នាំ | ចលនាឥណទាន | | ស្ថានភាព ឥណទានថ្មី | អនុវត្តជាក់ស្តែង | សមមាត្រ ប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | + | - | | | | |
| | | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧-៦/៥ | |
| | | | | | | | | | | | |
| | | | | សរុបរួម | | | | | | | |

| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខា | ហត្ថលេខា |
|---|---|---|---|---|
| ប្រធានរតនាគារខេត្ត.ក្រុង | អភិបាលខេត្ត.ក្រុង | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធានគណនេយ្យ | អ្នកធ្វើតារាង |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៣១៩ ពណ.នគក

ភ្នំពេញ ថ្ងៃទី ១១ ខែ ១៣ ឆ្នាំ ២០០៥

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **សៀងហៃ ខនស្ត្រាក់សិន គ្រុប (ខេមបូឌា)**
**SHANGHAI CONSTRUCTION GROUP (CAMBODIA) Co.,Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 2602/05E ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន :

| | | |
|---|---|---|
| លោក | **TONG JISHENG** | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក | **GONG GUONENG** | អភិបាល |
| លោក | **HE LUESA** | អភិបាល |
| លោកស្រី | **REN JUN** | អភិបាល |

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១៧ ផ្លូវ ៩៥ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញ គ្រប់ប្រភេទ
-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការដួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការដូសដុលសំភារៈទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកក័រដើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូនឥវ៉ាន់ទំនិញ ។

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

កឹម ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និង កីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៧៤០ ពណ.នគក

ភ្នំពេញថ្ងៃទី ១៧ ខែ ១០ ឆ្នាំ ២០០ ៥

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អូស៊ីអានា ស៊ីហ្វ៊ូដ ប្រូដាក់**
**OCEANIA SEAFOOD PRODUCTS Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8098/05P ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ទៅ ម៉េងអាន** ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី **ចំនួ ហ៊ុងអ៊ីង** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៣៥.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ០៤០ ផ្លូវលេខ ១០៨ ភូមិតាខ្មៅ ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្ដាល ។

៥- កម្មវត្ថុអាជីវកម្ម :
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ពិសេសរោងចក្រកែច្នៃផលនេសាទសមុទ្រ
-រោងចក្រផលិត និងជួសជុលនាវា
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្ដូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្ដូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកាំរ៉ៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD ។

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស-សេវាបញ្ជូននិងចែកចាយទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

ជ.**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**គឹម ស៊ីថន**

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលា ខេត្តកណ្តាល
- មន្ទីរពាណិជ្ជកម្មខេត្តកណ្តាល "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៤៣២៧ ពណ.នកក

ភ្នំពេញថ្ងៃទី ១១ ខែ ១៣ ឆ្នាំ ២០០៥

# ឯកសាររដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេហ្វ. ឌី. ហ្វាម៉ា**
**F. D. PHARMA Co.,Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8097/05P ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥
មានទម្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត
២- អភិបាលក្រុមហ៊ុន : លោក **ឈុន ហួត**
៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៣ BEoE1E2 ផ្លូវលេខ ២៨៤ សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ
៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ពិសេសនាំចូលគ្រឿងម៉ាស៊ីន ឧបករណ៍ និងគ្រឿងបន្លាស់គ្រប់ប្រភេទ សំរាប់បំរើអោយវិស័យកសិកម្មនិងឧស្សាហកម្ម ចំណីសត្វ ថ្នាំព្យាបាលសត្វ ថ្នាំសំលាប់សត្វល្អិត ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកក់វេជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស សេវាបញ្ជូនទំនិញ ចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ពិសេសផលិតឱសថ សំភារៈបរិក្ខារពេទ្យ ចំណីសត្វ ថ្នាំព្យាបាលសត្វ ថ្នាំសំលាប់សត្វល្អិត- សិប្បកម្ម កែច្នៃកសិផលនិងជលផលសំរាប់នាំចេញ ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ជួរលេខាធិការ

គឹម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៣២២ ពណ.នគក

ភ្នំពេញថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៥

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ចាន់ តារារស្មី ខូ អិលធីឌី**
**CHAN TARARAKSMEY CO.,LTD.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 8100/05P** ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន :
លោក **ជិន គឹមឡូន** ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី **អ៊ុំ ផល្លា** អភិបាល
លោក **ម៉ុន ឆារ៉ាំង** អភិបាល
លោក **អ៊ាង សុខណាយ** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២០ C ស្ថិតក្នុងដីឡូត៍លេខ ៣៦ C ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកក់រៃរជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជន...ប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស-សេវាបញ្ជូននិងចែកចាយទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។៚

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៦៣៦៣ ពណ.នគក

ភ្នំពេញថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៥

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ដួបូលី (ខេមបូឌា) អ៊ីមផត អិចផត**
**DUOBAOLI ( CAMBODIA ) IMPORT EXPORT Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8096/05P ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន :
លោក **ខ៊ូវ ម្នូច** ប្រធានក្រុមប្រឹក្សាភិបាល
លោក SOMBOON SAE- LOW អភិបាល
លោកស្រី **សុខ ឡៅ** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៣៧ Eo ផ្លូវលេខ ១៩៩ សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកតំរែជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្តវីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស-សេវាបញ្ជូននិងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។៤

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម សៀថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧៣៣១ ពណ.នតក

ភ្នំពេញថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៥

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **វីស៊ី មេនផៅវ៉ា**
**VC MANPOWER Co., Ltd**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8095/05P ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ឈូ ទិចិត្រ**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ១៨២ Eo ផ្លូវលេខ២៥៣ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំប្រើ[illegible] -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវា[illegible]ពាណិជ្ជកម្ម
-សេ[illegible]
-[illegible]

-ផលិតខ្សែភាពយន្ត វីដេអូ CD

